# (៣)

## ប្រកាសលេខ ៥២៣ សហវ.ប្រក
## ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកា
## របស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩២៣ សហវ.ប្រក

**ប្រកាស**
**ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច**
**នៃមាតិកាចំណាយរបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១៩១១សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ៨៣៨សហវ.ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានៃក្រសួង ស្ថាប័នថវិកាកម្មវិធី
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលចែកជាចំណាត់ថ្នាក់ចំណូល ចំណាយ និងត្រូវបានបែងចែក ជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣.-**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

<u>ចម្លងជូន:</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង ស្ថាប័ន
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២ មាតិកាចំណាយថវិកា

ភ្ជាប់ជាមួយប្រកាសលេខ [illegible] សហវ.ប្រក ចុះថ្ងៃទី០៩ ខែ[illegible] ឆ្នាំ ២០១៧

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់អំពីមាតិកាថវិកា |
|---|---|---|---|---|
| | | | សរុបរួមចំណាយថវិកា (ក+ខ) | សរុបចំណាយចរន្ត និងសរុបចំណាយមូលធន។ |
| | | | ក. សរុបចំណាយចរន្ត (ក្រុមទី១+ក្រុមទី២) | ចំណាយជាប្រចាំដែលប្រមូលផ្តុំនូវគណនីទាំងឡាយសម្រាប់កត់ត្រាល់បន្ទុកតាមប្រភេទនីមួយៗ ក្នុងនោះមាន÷ ចំណាយពិត, ចំណាយតាមដីកា និង ចំណាយមិនបានគ្រោងទុក។ |
| | | | ក្រុមទី១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២ + ប្រភេទទី៣ + ប្រភេទទី៤) | ចំណាយជាសាច់ប្រាក់ជាក់ស្តែងដែលក្នុងនោះរួមមាន÷ ចំណាយមធ្យោបាយសេវា, បន្ទុកហិរញ្ញវត្ថុ, អន្តរាគមន៍សាធារណៈ, ចំណាយផ្សេងៗ និងការសងនិងការបង្វិលវិញ។ |
| | | | ប្រភេទទី១ : មធ្យោបាយ និងសេវា | ចំណាយដើម្បីទទួលបាននូវមធ្យោបាយនិងសេវាផ្សេងៗ ដែលរួមមាន÷ ទំនិញ, សេវាកម្ម, និងបន្ទុកបុគ្គលិក។ |
| 60 | | | ការទិញ | កត់ត្រាចំណាយលើការទិញសម្ភារសម្រាប់ការងារថែទាំនិងជួសជុលទាំងឡាយណាដែលធ្វើដោយរដ្ឋ និងការទិញសម្ភារផ្គត់ផ្គង់រដ្ឋបាល ស្បៀងអាហារនិងផលិតផលកសិកម្ម, សំលៀកបំពាក់និងការតុបតែង, សម្ភារត្បូចបាច, សង្ហារឹម, និងសម្ភារបរិក្ខារ, ការប្រើប្រាស់ថាមពលនិងទឹក សម្ភារបរិក្ខារថែទាំសុខភាព, និងសម្ភារផ្គត់ផ្គង់ផ្សេងៗ។ |
| | 6001 | | សម្ភារផ្គត់ផ្គង់ថែទាំ | ចំណាយលើសម្ភារផ្គត់ផ្គង់ ប្រេងឥន្ធនៈ និងប្រេងរំអិល ដែលពាក់ព័ន្ធនឹងការងារថែទាំនិងជួសជុលទ្រព្យសង្ហារឹម, និងទ្រព្យអសង្ហារឹម។ |
| | | 60011 | សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ | ចំណាយលើការទិញសម្ភារសម្រាប់សម្អាតនិងអនាម័យ ដូចជា÷ អំបោស, សាប៊ូ, ទឹកលាងកញ្ចក់, ក្រដាសអនាម័យ, ទឹកក្រអូបបាញ់បន្ទប់, ច្រាស់, កន្សែងដៃ, ថ្នាំបាញ់មូស។ល។ |
| | | 60012 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និង សំណង់ផ្សេងៗ | ចំណាយលើការទិញសម្ភារសម្រាប់ថែទាំនិងជួសជុលអគារ, សួនច្បារ, របង, ចំណតរថយន្ត, បន្ទប់ទឹក, ឃ្លាំង, ប្រាសាទ, អាកាសយានដ្ឋាន, កំពង់ផែ។ល។ |
| | | 60013 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ | ចំណាយលើការទិញសម្ភារផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់, ស្ពាន, លូ (ដែលការងារថែទាំនេះធ្វើដោយមន្ត្រីរបស់អង្គភាពសាមី) ដូចជា÷ ខ្សាច់, ស៊ីម៉ង់, គ្រួស, ដី, កំបោរ, ឥដ្ឋ, ដែក, ថ្នាំលាប។ល។ |
| | | 60014 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារឧបករណ៍ | ចំណាយលើការទិញសម្ភារផ្គត់ផ្គង់សម្រាប់ថែទាំនិងជួសជុលសម្ភារនិងឧបករណ៍ ក្នុងគណនី៦០០៥ និងគណនី២១០[illegible] ដូចជា÷ គ្រឿងបន្លាស់ ផ្សេងៗ, កង់ឡាន, កង់ម៉ូតូ, ប៊ូស៊ី។ល។ |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | ចំណាយលើការទិញប្រេងឥន្ធនៈនិងប្រេងរំអិលសម្រាប់ថែទាំ និងដំណើរការយានយន្តនិងគ្រឿងម៉ាស៊ីនផ្សេងៗ [illegible] និង សកម្មភាពការងាររបស់អង្គភាព។ |
| | | 60018 | សម្ភារផ្គត់ផ្គង់ថែទាំផ្សេងៗ | ចំណាយលើការទិញសម្ភារផ្គត់ផ្គង់ថែទាំទ្រព្យសង្ហារឹមនិងទ្រព្យអសង្ហារឹមផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6002 | | សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល | ចំណាយលើការទិញសម្ភារការិយាល័យ, ការបោះពុម្ព, សៀវភៅមើល, និងឯកសារផ្សេងៗ សម្រាប់ដំណើរការរដ្ឋបាល។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាជំពូក |
|---|---|---|---|---|
| | | 60021 | សម្ភារការិយាល័យ | ចំណាយលើការទិញសម្ភារការិយាល័យ និងសម្ភារប្រឡង ដូចជា÷ ក្រដាសក្រម, ខ្មៅដៃ, ប៊ិច, ហ្វីត, ស៊ីមី, ទឹកថ្នាំម៉ាស៊ីនបោះពុម្ពឯកសារ, ទឹកថ្នាំម៉ាស៊ីនថតចម្លង, សៀវភៅមូលប្បទានប័ត្រ។ល។ |
| | | 60022 | សៀវភៅមើល និងឯកសារ | ចំណាយលើការទិញសៀវភៅមើលនិងឯកសារផ្សេងៗ ដែលបម្រើឱ្យការងាររដ្ឋបាល ដូចជា÷ វចនានុក្រម, សៀវភៅច្បាប់។ល។ |
| | | 60023 | ការបោះពុម្ព | ចំណាយលើការបោះពុម្ព ដូចជា÷ បោះពុម្ពសៀវភៅ, ឯកសារ, បង្កាន់ដៃបង់ប្រាក់, តែមប្រើ, ទិដ្ឋាការ, លតាប័ត្រ។ល។ |
| | | 60028 | សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ | ចំណាយលើការទិញសម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6003 | | ស្បៀងអាហារ និងផលិតផលកសិកម្ម | ចំណាយលើការទិញអាហារ និងភេសជ្ជៈសម្រាប់រដ្ឋបាល (ក្រៅពីការទទួលភ្ញៀវ, ការប្រជុំ, វគ្គបណ្តុះបណ្តាល, និងសិក្ខាសាលា) និងចំណាយលើការទិញផលិតផលចាំបាច់បម្រើឱ្យវិស័យកសិកម្ម។ |
| | | 60031 | ស្បៀង | ចំណាយទិញអង្ករ និងស្បៀងអាហាររដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា÷ អង្ករ, មី, ត្រីខ, ទឹកត្រី, ស្ករ, អំបិល។ល។ |
| | | 60032 | ចំណីសត្វ | ចំណាយលើការទិញស្មៅក្រៀម និងចំណីសត្វ។ល។ |
| | | 60033 | ពូជ និងកូនរុក្ខជាតិ | ចំណាយលើការទិញគ្រាប់ពូជ, កូនឈើ, ដើមផ្កា។ល។ |
| | | 60034 | ផលិតផលការពារសុខុមាលភាពរុក្ខជាតិ និងដី | ចំណាយលើការទិញផលិតផលដើម្បីការពាររុក្ខជាតិ ដូចជា÷ ថ្នាំសំលាប់សត្វល្អិត, សំណាញ់, ដី។ល។ |
| | | 60035 | ពូជសត្វ | ចំណាយលើការទិញពូជសត្វដូចជា÷ ពូជត្រី, មាន់, ជ្រូក, គោ។ល។ |
| | | 60036 | ឱសថ និងវត្ថុធាតុសម្រាប់បសុពេទ្យ | ចំណាយលើការទិញឱសថ និងវត្ថុធាតុសម្រាប់បង្ការ និងព្យាបាលសត្វ។ |
| | | 60037 | ស្បៀងសម្រាប់រដ្ឋបាល | ចំណាយលើការទិញ ស្បៀងសម្រាប់ដំណើរការរដ្ឋបាល ដូចជា÷ ផ្លែឈើ, ទឹក, នំ, ភេសជ្ជៈ, តែ, កាហ្វេ។ល។ |
| | | 60038 | ស្បៀងអាហារ និងផលិតផលកសិកម្មផ្សេងៗ | ចំណាយលើការទិញស្បៀងអាហារ និងផលិតផលកសិកម្មផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6004 | | សំលៀកបំពាក់ និងការតុបតែង | ចំណាយលើការផ្គត់ផ្គង់ឯកសណ្ឋាន, សំលៀកបំពាក់ការពារសុវត្ថិភាព, មេដាយ, សញ្ញាសក្តិ, និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ជូនមន្ត្រីមានសមត្ថកិច្ច និងមន្ត្រីរាជការដែលតម្រូវឱ្យមានឯកសណ្ឋានតាមច្បាប់កំណត់។ |
| | | 60041 | ឯកសណ្ឋាន | ចំណាយលើការផ្គត់ផ្គង់ឯកសណ្ឋានជូនមន្ត្រីមានសមត្ថកិច្ច ដូចជា÷ មន្ត្រីរាជការស៊ីវិល, កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ, មន្ត្រីជាប់កិច្ចសន្យា, និងក្រុមប្រឹក្សា ដែលតម្រូវឱ្យមានឯកសណ្ឋានតាមច្បាប់កំណត់ ដោយរួមទាំងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ដូចជា÷ មួក, សញ្ញាសក្តិ។ល។ |
| | | 60042 | សំលៀកបំពាក់ការពារសុវត្ថិភាព | ចំណាយលើការទិញសំលៀកបំពាក់ការពារសុវត្ថិភាព ជូនមន្ត្រីមានសមត្ថកិច្ច និងមន្ត្រីរាជការក្នុងពេលបំពេញការងារដូចជា÷ [illegible] សុវត្ថិភាព, ស្បែកជើង មួក។ល។ |
| | | 60043 | មេដាយ(គ្រឿងឥស្សរិយយស) | ចំណាយលើការផ្គត់ផ្គង់មេដាយ(គ្រឿងឥស្សរិយយស), លិខិត, និងប័ណ្ណសរសើរ ជូនបុគ្គលិកនិងមន្ត្រីមានសមត្ថកិច្ច និងមន្ត្រី[illegible] ការងារបានល្អ។ |
| | | 60048 | សំលៀកបំពាក់ និងការតុបតែងផ្សេងៗ | ចំណាយលើការផ្គត់ផ្គង់សំលៀកបំពាក់ និងការតុបតែងផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6005 | | សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ | ចំណាយលើការទិញសម្ភារគ្រប់ប្រភេទ ដូចជា÷ សម្ភារបរិក្ខារបច្ចេកទេស, សង្ហារឹម, សម្ភារតូចតាចសម្រាប់ប្រើប្រាស់, និងសម្ភារ[illegible] ជញ្ជូន ។ល។ ដែលមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ចំណាយជាមូលធន។ |

| ជំពូក | គណនី | អនុគណនី | ចរិយាយ | សេចក្ដីពន្យល់ពីមាតិកាជំពូក |
|---|---|---|---|---|
| | | 60051 | សម្ភារនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា | ចំណាយលើការទិញសម្ភារ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា ដូចជា÷ ដំបងរត់, របាំងការពារផ្សេង, ទូទឹកកក, ម៉ាស៊ីនត្រជាក់, ម៉ាស៊ីនភ្លើង, ម៉ាស៊ីនបូមទឹក, បំពង់ពន្លត់អគ្គីភ័យ, អាគុយ, ឧបករណ៍បំពងសម្លេង។ល។ |
| | | 60052 | សង្ហារឹម | ចំណាយលើការទិញគ្រឿងសង្ហារឹម ដូចជា÷ តុ, ទូដាក់ឯកសារ, សាឡុង, កៅអី។ល។ |
| | | 60053 | សម្ភារប្រើប្រាស់ | ចំណាយលើការទិញសម្ភារប្រើប្រាស់ ដូចជា÷ សម្ភារកីឡាគ្រប់ប្រភេទ, ថ្នាំពិលគ្រប់ប្រភេទ, ហ្វីលថត (អង្គចងចាំ), កាសែតថតសំលេង, កាសែតវីដេអូ, ញញួរ, សោរបោក, ម៉ាស៊ីនបោះ ឬ ខ្នង, ម៉ាស៊ីនខាត់, ចប, តង់កៅស៊ូ, រណា, កាំងនទ។ល។ |
| | | 60054 | សម្ភារ និងឧបករណ៍ដឹកជញ្ជូន | ចំណាយលើការទិញសម្ភារនិងឧបករណ៍ដឹកជញ្ជូន ដែលមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ចំណាយមូលធន ដូចជា÷ រទេះរុញ, រថយន្ត, ម៉ូតូ, កង់។ល។ |
| | | 60055 | សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា | ចំណាយលើការទិញសម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា ដូចជា÷ កុំព្យូទ័រ, ព្រីនធ័រ, ម៉ាស៊ីនថត, ទូរស័ព្ទ, ម៉ាស៊ីនហ្វូតូកូពី, ម៉ាស៊ីនស្កេន។ល។ |
| | | 60058 | សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារផ្សេងៗ | ចំណាយលើការទិញសម្ភារតូចតាច, សង្ហារឹម, និងសម្ភារបរិក្ខារផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6006 | | ថាមពលនិងទឹក | ចំណាយលើការប្រើប្រាស់ថាមពល និងទឹក។ |
| | | 60061 | អគ្គិសនី | ចំណាយលើការប្រើប្រាស់ថាមពលអគ្គិសនី។ |
| | | 60062 | ទឹក | ចំណាយលើការប្រើប្រាស់ទឹក។ |
| | | 60068 | ផ្សេងៗ | ចំណាយលើការប្រើប្រាស់ថាមពលផ្សេងៗទៀត ដូចជា÷ ធ្យូងថ្ម, ហ្គាស។ល។ |
| | 6007 | | សម្ភារបរិក្ខារថែទាំសុខភាព | ចំណាយលើការទិញផលិតផល សម្ភារបរិក្ខារថែទាំសុខភាព ដែលប្រើប្រាស់ផ្ទាល់ដោយភ្នាក់ងាររបស់រដ្ឋ សម្រាប់ថែទាំសុខភាពជូនប្រជាជន ដូចជា÷ បំពង់ហ្គាសនិងអុកស៊ីសែន, សម្ភារបរិក្ខារពេទ្យ។ល។ |
| | | 60071 | បំពង់ហ្គាសនិងអុកស៊ីសែន | ចំណាយលើការទិញបំពង់ហ្គាសនិងខ្យល់អុកស៊ីសែន។ |
| | | 60072 | សម្ភារបរិក្ខារពេទ្យ | ចំណាយលើការទិញសម្ភារបរិក្ខារពេទ្យ ដូចជា÷ ប្រតិករគីមីសម្រាប់មន្ទីរពិសោធន៍, សម្ភាររបស់និសិតការី, គ្រែពេទ្យ, ឧបករណ៍វះកាត់, គ្រែដេកធ្មេញ, បំពង់ពិសោធន៍, ឧបករណ៍វាស់ស្ទង់។ល។ |
| | | 60078 | សម្ភារបរិក្ខារថែទាំសុខភាពផ្សេងៗ | ចំណាយលើការទិញបរិក្ខារថែទាំសុខភាពផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6098 | | សម្ភារផ្គត់ផ្គង់ផ្សេងៗ | ចំណាយលើការទិញសម្ភារផ្គត់ផ្គង់ផ្សេងៗទៀត ក្រៅពីគណនីខាងលើ និងមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ចំណាយជាមូលធន។ |
| | | 60981 | សម្ភារផ្គត់ផ្គង់ផ្សេងៗ | ចំណាយលើការទិញសម្ភារផ្គត់ផ្គង់ផ្សេងៗទៀត ក្រៅពីគណនីខាងលើ និងមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ចំណាយជាមូលធន។ |
| 61 | | | សេវាកម្ម | ជំពូកនេះកត់ត្រារាល់ចំណាយលើសេវាខាងក្រៅ ដែលផ្ដល់ដោយសហគ្រាស អង្គភាពរដ្ឋ ឬ ក្រុមហ៊ុនឯកជនជាប់បន្ទប់បុគ្គល និងផ្សេងៗ។ |
| | 6101 | | កិច្ចសន្យានៃការផ្ដល់សេវាជាមួយសហគ្រាស | ការចំណាយដែលចេញវិក្កយប័ត្រដោយសហគ្រាសឯកជន ដែលបានផ្ដល់នូវសេវាសាធារណៈដូចជា÷ សេវាអនាម័យ, សេវាថ្មីបាល |
| | | 61011 | សេវាអនាម័យ | ការចំណាយលើការផ្ដល់សេវាពីសហគ្រាសឯកជន ក្នុងទម្រង់ជាការប្រមូលសំណល់រឹង រាវ តាមទីប្រជុំជនដូចជា÷ ការដឹកសំរាម, ការសម្អាតផ្លូវ, សួនច្បារ, ការថែសួនច្បារ, និងក្នុងទម្រង់ជាសកម្មភាពសម្អាត ថែទាំ និងការពារបរិស្ថានទីប្រជុំជន។ល។ |
| | | 61012 | សេវារដ្ឋបាល | ចំណាយលើសេវាបម្រើដល់ការងាររដ្ឋបាល ដូចជា÷ ការជួលម៉ាស៊ីនថតចម្លង, ម៉ាស៊ីនព្រីនធ័រសម្រាប់, បោះពុម្ពឯកសារ, ម៉ាស៊ីនភ្លើង។ល។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 61018 | សេវាផ្សេងៗ | ការចំណាយលើសេវាផ្សេងៗទៀតជាមួយសហគ្រាស ក្រៅពីអនុគណនីខាងលើ។ |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | ចំណាយលើការជួលមធ្យោបាយដឹកជញ្ជូន ដូចជា÷ កង់, ម៉ូតូ, រថយន្ត, និងមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត។ |
| | | 61021 | ការជួលមធ្យោបាយដឹកជញ្ជូន | ចំណាយលើការជួលមធ្យោបាយដឹកជញ្ជូន ដូចជា÷ កង់, ម៉ូតូ, រថយន្ត។ល។ |
| | | 61028 | ការជួលមធ្យោបាយដឹកជញ្ជូនផ្សេងៗ | ចំណាយលើការជួលមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6103 | | ថ្លៃឈ្នួល និងបន្ទុក(អសង្ហារិម) ក្នុងនិងក្រៅប្រទេស | ថ្លៃឈ្នួលលើការជួលផ្ទះ, អគារ, ទីតាំង ក្នុងនិងក្រៅប្រទេស សម្រាប់បម្រើឱ្យការងាររដ្ឋបាល។ |
| | | 61031 | ថ្លៃឈ្នួល និងបន្ទុក(អសង្ហារិម) ក្នុងប្រទេស | ថ្លៃឈ្នួលលើការជួលផ្ទះ, អគារ, ទីតាំង ក្នុងប្រទេស សម្រាប់បម្រើឱ្យការងាររដ្ឋបាល និងសកម្មភាពការងាររបស់អង្គភាព ដូចជា÷ កន្លែង-ធ្វើការទីតាំងហ្វឹកហាត់។ល។ |
| | | 61032 | ថ្លៃឈ្នួល និងបន្ទុក(អសង្ហារិម) ក្រៅប្រទេស | ថ្លៃឈ្នួលលើការជួលផ្ទះ, អគារ, ទីតាំង ក្រៅប្រទេស សម្រាប់បម្រើឱ្យការងាររដ្ឋបាល និងសកម្មភាពការងាររបស់អង្គភាព ដូចជា÷ កន្លែងធ្វើការ, កន្លែងស្នាក់នៅ របស់មន្ត្រីការទូតនៅក្រៅប្រទេស។ល។ |
| | | 61038 | ថ្លៃឈ្នួល និងបន្ទុក(អសង្ហារិម) ផ្សេងៗ | ថ្លៃឈ្នួល និងបន្ទុកផ្សេងៗ ក្រៅពីអនុគណនីខាងលើ។ |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាល ក្នុងនិងក្រៅប្រទេស | ចំណាយដែលទាក់ទងនឹងការបណ្តុះបណ្តាល មានដូចជា÷ ការរៀបចំឯកសារនិងសម្ភារឧបទេស, ការជួលទីតាំងនិងការរៀបចំទីកន្លែង, ការ-ឧបត្ថម្ភគ្រូឧទ្ទេស និងអ្នកសម្របសម្រួល និងចំណាយផ្សេងៗ បម្រើឱ្យសកម្មភាពការបណ្តុះបណ្តាល ព្រមទាំងការទូទាត់ជូនអ្នកជំនាញការដែលមិនមែនជាមន្ត្រីរាជការ និងការបង់ថ្លៃសាលា ក្នុងនិងក្រៅប្រទេស។ ករណីការបណ្តុះបណ្តាលដែលតម្រូវឱ្យមានបេសកកម្ម÷ ត្រូវប្រើគណនី ៦១១២ សម្រាប់ទូទាត់សោហ៊ុយបេសកកម្មក្នុងប្រទេស និងប្រើគណនី៦១១៣ សម្រាប់ទូទាត់សោហ៊ុយបេសកកម្មក្រៅប្រទេស។ |
| | | 61041 | សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | ចំណាយដែលទាក់ទងនឹងការបណ្តុះបណ្តាល មានដូចជា÷ ការរៀបចំឯកសារនិងសម្ភារឧបទេស ការជួលទីតាំងនិងការរៀបចំទីកន្លែង, ការ-ឧបត្ថម្ភគ្រូឧទ្ទេស និងអ្នកសម្របសម្រួល និងចំណាយផ្សេងៗ បម្រើឱ្យសកម្មភាពការបណ្តុះបណ្តាល ព្រមទាំងការទូទាត់ជូនអ្នកជំនាញការដែលមិនមែនជាមន្ត្រីរាជការ និងការបង់ថ្លៃសាលា ក្នុងនិងក្រៅប្រទេស។ ករណីការបណ្តុះបណ្តាលដែលតម្រូវឱ្យមានបេសកកម្ម÷ ត្រូវប្រើគណនី ៦១១២ សម្រាប់ទូទាត់សោហ៊ុយបេសកកម្មក្នុងប្រទេស និងប្រើគណនី៦១១៣ សម្រាប់ទូទាត់សោហ៊ុយបេសកកម្មក្រៅប្រទេស។ |
| | | 61048 | សោហ៊ុយបណ្តុះបណ្តាលផ្សេងៗ ក្នុងនិងក្រៅប្រទេស | ចំណាយលើសោហ៊ុយបណ្តុះបណ្តាលផ្សេងៗទៀត ក្នុងនិងក្រៅប្រទេស ក្រៅពីអនុគណនីខាងលើ។ |
| | 6105 | | ការថែទាំនិងជួសជុល | ចំណាយលើការថែទាំ និងជួសជុលដែលអនុវត្តដោយក្រុមហ៊ុនឬសហគ្រាសឯកជនជានីតិបុគ្គល និងរូបវន្តបុគ្គល និងអង្គភាព[illegible] ប៉ុន្តែ ប្រសិនបើការងារថែទាំនិងជួសជុលនេះអនុវត្តដោយភ្នាក់ងាររបស់រដ្ឋ ការចំណាយលើការទិញសម្ភារត្រូវកត់ត្រាក្នុងជំពូក៦០( [illegible] បុគ្គលិកត្រូវកត់ត្រាក្នុងជំពូក៦៤ (បន្ទុកបុគ្គលិក)។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់អំពីមាតិកាជាថវិកា |
|---|---|---|---|---|
| | | 61051 | ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងវាលនេសាទ | ចំណាយលើការថែទាំ, ដីធ្លី, សួនច្បារ, ព្រៃឈើ, តំបន់ឆ្នេរ, និងច្រាំងទន្លេ ស្ទឹង ដូចជា÷ ចំណាយលើការកាប់ឆ្ការព្រៃ, ភ្ជួររាស់ដី, ចាក់ដីបំពេញ, សោហ៊ុយរាស់វែងដី, ធ្វើថ្នល់, ការស្តារស្រះ, ត្រពាំង, បឹងបួ, ទន្លេ។ល។ |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | ចំណាយលើការថែទាំ ជួសជុលអគារ និងប្រាសាទ ដូចជា÷ ចំណាយជួសជុលរោងការ, របងអគារ, ចំណតរថយន្ត, បន្ទប់ទឹក, ឃ្លាំង, ប្រាសាទ, អាកាសយានដ្ឋាន, កំពង់ផែ, ទីផ្សារ, សត្តឃាតដ្ឋាន (សួនច្បារក្នុងទីធ្លា) ដែលមានការផ្គត់ផ្គង់សេវាពីខាងក្រៅ ព្រមទាំងចំណាយលើការងារលាបថ្នាំ, ការរៀបចំបណ្តាញឡើងវិញ ដែលបណ្តាលមកពីការជួសជុលអគារ លើកលែងចំណាយទូទាត់ថ្លៃទិញឧបករណ៍ថ្មីបំពាក់បន្ថែម ដែលត្រូវកត់ត្រាក្នុងជំពូក៦០ (ការទិញ)។ |
| | | 61053 | ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | ចំណាយលើការងារថែទាំនិងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ រួមមាន÷ (១)ការងារថែទាំផ្លូវថ្នល់ជាប្រចាំ សំដៅលើការងារទាំងឡាយ ដែលធ្វើឡើងដើម្បីធានានិរន្តរភាព និងសុវត្ថិភាពនៃការធ្វើចរាចរ ព្រមទាំងដើម្បីរក្សាឬបង្កើនអាយុកាលនៃការប្រើប្រាស់ផ្លូវថ្នល់ ស្ពាននិងលូ មានដូចជា÷ ការងារជួសជុលលុបរង្វង់កំបុកមាន់, ស្រោចកៅស៊ូលើស្នាមប្រេះ, ប៉ះតែមគូផ្លូវថ្នល់, ក្រាលកៅស៊ូពីលើផ្លូវដែលសឹករិចរិល និងផតស្រុត, បំពេញក្រួសក្រហមចិញ្ចើម, កាប់ព្រៃសងខាងផ្លូវ, សាងសង់ ជួសជុល និងលាបថ្នាំស្លាកសញ្ញាចរាចរ,បង្គោលគីឡូម៉ែត្រ, គូសគំនូសចរាចរ, ជួសជុលនិងបំពាក់សម្ភារៈបរិក្ខារផ្លូវថ្នល់, ជួសជុលកៀរសម្រួលនិងថែមក្រួសក្រហមតួថ្នល់, ជួសជុលនិងថែទាំស្ពាន កម្រិតតូចនិងមធ្យម, ការស្តារប្រឡាយនិងលូតាមដងផ្លូវថ្នល់, និង ការងារគាំទ្រការថែទាំផ្សេងទៀតដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិផ្លូវថ្នល់។ល។ (២)ការងារជួសជុលខួប (ជួសជុលផ្លូវទ្រង់ទ្រាយធំ និងលក្ខណៈខួប) គឺជាការងារទាំងឡាយដែលការងារថែទាំជាប្រចាំមិនអាចទ្រទ្រង់បាន ដូចជា÷ ការជួសជុលផ្ទៃផ្លូវឡើងវិញដោយក្រាលក្រួសក្រហម ក្រាលកៅស៊ូ និងក្រាលបេតុង និងជួសជុល ស្ពារ សំណង់សិល្បការ ។ល។ (៣)ការងារអន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវថ្នល់ ស្ពាននិងលូ គឺជាការងារជួសជុលផ្លូវថ្នល់ ស្ពាននិងលូទាំងឡាយណា ដែលត្រូវបានកាត់ផ្តាច់ ឬ បាក់ឬរកកលនឹងដាច់ ឬ បាក់ ដោយគ្រោះធម្មជាតិ ឬគ្រោះថៃដន្យយថាហេតុណាមួយ ដើម្បីឱ្យចរាចរដំណើរការបានជាប្រក្រតី។ (៤)ការងារគាំទ្រការជួសជុលនិងថែទាំផ្លូវថ្នល់ គឺជាការងារទាំងឡាយណាដែលអនុវត្តសម្រាប់គាំទ្រការងារជួសជុលនិងថែទាំផ្លូវថ្នល់ ស្ពាន និងលូ ដូចជា÷ការសិក្សាលមិទ្ធិបឋម, ការសិក្សា និងគំនូសប្លង់(Design)គម្រោង,ការរាប់ចំនួនចរាចរ, ការត្រួតពិនិត្យផ្លូវថ្នល់ និងស្ពានជាទៀងទាត់, ការសិក្សានិងស្រាវជ្រាវបច្ចេកទេសផ្លូវថ្នល់និងស្ពាន និងការងារទប់ស្កាត់ការបើកជញ្ជូនលើសទម្ងន់កំណត់ និងការពារការខូចខាតផ្លូវថ្នល់ ស្ពាន និងលូ (ស្ថានីយ៍ត្រួតពិនិត្យយានយន្តដឹកទម្ងន់លើសកម្រិតកំណត់ ការផ្សព្វផ្សាយ... ចំណីផ្លូវ។ល។)។ |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | ចំណាយលើការងារជួសជុលថែទាំគ្រប់ប្រព័ន្ធបណ្តាញទាំងអស់ដែលមិនមែនជាផ្លូវចរាចរ ហើយមិនពាក់ព័ន្ធនឹងការជួសជុល... បណ្តាញលូ ទឹកស្អាត ភ្លើងអគ្គិសនី តបណ្តាញអគ្គិសនី បណ្តាញទូរស័ព្ទ ប្រព័ន្ធបណ្តាញព័ត៌មានវិទ្យា(Network Infrastructure) ។ល។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 61055 | ការថែទាំប្រព័ន្ធធារាសាស្ត្រ | ចំណាយលើការងារជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រ រួមមាន÷ (១)ចំណាយកិច្ចដំណើរការ សំដៅលើ ការឧបត្ថម្ភដល់អ្នកយាមបិទបើកទ្វារទឹក, ការងារត្រួតពិនិត្យស្ថានភាពប្រព័ន្ធធារាសាស្ត្រជារួម, ការតាមដានកម្ពស់ទឹក, និងការងារសម្របសម្រួលការបែងចែកទឹក។ល។ (២)ការការថែទាំជាប្រចាំប្រព័ន្ធធារាសាស្ត្រ សំដៅលើការងារថែទាំអាងស្តុកទឹក, ប្រឡាយមេ, ប្រឡាយមេទី២, ប្រឡាយរង, ប្រឡាយជើងក្អែប,ភ្លឺប្រឡាយ, ទំនប់, ជើងទេរប្រឡាយ, ដាំស្មៅជើងទេរ, ទ្វារទឹក, សំណង់ស្ពាន/បញ្ចេញ/ចែកចាយទឹក សំណង់សិល្បៈការផ្សេងៗ និងការងារគាំទ្រកិច្ចដំណើរការនិងថែទាំប្រព័ន្ធធារាសាស្ត្រ ។ល។ (៣)ការងារជួសជុលខួប (ការងារជួសជុលទ្រង់ទ្រាយធំ ឬស្តារឡើងវិញដែលមានលក្ខណៈខួប) សំដៅលើ ការងារជួសជុលប្រព័ន្ធធារាសាស្ត្រទាំងឡាយណាដែលការងារថែទាំជាប្រចាំមិនអាចទ្រទ្រង់បាន ដោយជួសជុលអាងស្តុកទឹក, ប្រឡាយមេ, ប្រឡាយមេទី២, ប្រឡាយរង, ប្រឡាយជើងក្អែប,ភ្លឺប្រឡាយ, ទំនប់, ជើងទេរប្រឡាយ, ដាំស្មៅជើងទេរ, ទ្វារទឹក, សំណង់ស្ពាន/បញ្ចេញ/ចែក- ចាយទឹក, សំណង់សិល្បៈការផ្សេងៗ។ល។ (៤)ការងារអន្តរាគមន៍បន្ទាន់ជួសជុលប្រព័ន្ធធារាសាស្ត្រ សំដៅលើការងារជួសជុលប្រព័ន្ធធារាសាស្ត្រទាំងឡាយណាដែលកំពុងដំណើរការ ហើយត្រូវបានខូចខាត កាត់ផ្តាច់ ឬរកកលនិងដាច់ ឬ ខូចខាតដោយគ្រោះធម្មជាតិ ឬគ្រោះថៃផ្សេងណាមួយ ឱ្យមកដំណើរការប្រក្រតីវិញ និងការងារអន្តរាគមន៍កាត់ផ្តាច់ ឬ តភ្ជាប់ទំនប់/ប្រឡាយដែលទទួលរងសម្ពាធទឹកខ្លាំងដើម្បីបញ្ចៀសការលិចលង់ ។ល។ (៥)ការងារគាំទ្រសហគមន៍កសិករប្រើប្រាស់ទឹក រួមមាន÷ ការងារគាំទ្ររដ្ឋបាល, ការងារផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេស, ការងារដំណើរការនិងថែទាំប្រឡាយរងតូចៗ, ការងារជួសជុលប្រឡាយរងតូចៗ និងការងារគាំទ្រផ្សេងទៀត។ល។ |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | ចំណាយដែលពាក់ព័ន្ធនឹងការងារថែទាំនិងជួសជុលយានយន្ត និងជលយានដែលជាទ្រព្យសម្បត្តិរបស់អង្គភាព (សោហ៊ុយយានដ្ឋាន)។ |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស | ចំណាយលើការថែទាំនិងជួសជុលសម្ភារនិងឧបករណ៍បច្ចេកទេស ដូចជា÷ សម្ភារសាធារណការ(គ្រឿងចក្រ), ម៉ាស៊ីនត្រជាក់, ម៉ាស៊ីនថតចម្លង, ទូរស័ព្ទ, វិទ្យុទាក់ទង, ម៉ាស៊ីនហ្វាក់, កុំព្យូទ័រ, ម៉ាស៊ីនផ្សាយទូរទស្សន៍។ល។ |
| | | 61058 | ការថែទាំនិងជួសជុលផ្សេងៗ | ចំណាយលើការថែទាំនិងជួសជុលផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6106 | | សោហ៊ុយធានារ៉ាប់រង | ចំណាយលើសោហ៊ុយធានារ៉ាប់រងលើអគារ, យានយន្ត, សុខភាព។ល។ |
| | | 61061 | សោហ៊ុយធានារ៉ាប់រងលើអគារ | ចំណាយលើសោហ៊ុយធានារ៉ាប់រងលើអគារ។ |
| | | 61062 | សោហ៊ុយធានារ៉ាប់រងលើយានយន្ត | ចំណាយលើសោហ៊ុយធានារ៉ាប់រងលើយានយន្ត។ |
| | | 61063 | សោហ៊ុយធានារ៉ាប់រងលើសុខភាព | ចំណាយលើសោហ៊ុយធានារ៉ាប់រងលើសុខភាព។ |
| | | 61068 | សោហ៊ុយធានារ៉ាប់រងផ្សេងៗទៀត | ចំណាយលើសោហ៊ុយធានារ៉ាប់រងផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍, សោហ៊ុយនៃការប្រើ-ប្រាស់សេវា, សោហ៊ុយនៃការប្រើប្រាស់សិទ្ធិនិងសំណងផ្សេងៗ | ចំណាយលើការសិក្សាពិសោធន៍និងចំណាយលើសោហ៊ុយដើម្បីទទួលបានផ្លូវការប្រើប្រាស់សេវានិងសិទ្ធិ ដែលមិនទាក់ទងនឹងក្នុងគិរិយាសម្រាប់។ |
| | | 61071 | សោហ៊ុយសិក្សាពិសោធន៍ | ចំណាយលើសោហ៊ុយសិក្សាពិសោធន៍ ដូចជា÷ ការសិក្សាលើប្រជាសាស្ត្រ, សិក្សាពីតម្រូវការ, ការជួលម៉ូដែលសម្រាប់សិក្សាស្រាវជ្រាវ។ល។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាចំណាយ |
|---|---|---|---|---|
| | | 61072 | សោហ៊ុយនៃការប្រើប្រាស់សេវា | ចំណាយលើការបង់សោហ៊ុយផ្សេងៗ ដើម្បីទទួលបាននូវការប្រើប្រាស់សេវា ដូចជា៖ ការជួលមេធាវី, ការជួលភ្នាក់ងារអចលកម្ម, សោហ៊ុយបកប្រែឯកសារ (ក្រៅពីមុខសញ្ញាចំណាយលើវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ក្នុងគណនី៦១០៤ និងអនុគណនី ៦១១០៣)។ល។ |
| | | 61073 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | ចំណាយលើការបង់សោហ៊ុយផ្សេងៗដើម្បីទទួលបាននូវការប្រើប្រាស់សិទ្ធិ ដូចជា៖ សិទ្ធិថតចម្លង, សិទ្ធិផ្សព្វផ្សាយ, សិទ្ធិប្រើប្រាស់ផ្នែកព័ត៌មានវិទ្យា។ល។ |
| | | 61074 | សំណងផ្នែកស៊ីវិល | ចំណាយឧបត្ថម្ភជាប្រាក់គោលនយោបាយដល់ប្រជាជនជាថ្នូរដល់ការយកហូតដីធ្លីឬផ្ទះសម្បែង ទុកជាទ្រព្យសម្បត្តិរដ្ឋ ដើម្បីជាគុណប្រយោជន៍សាធារណៈ។ |
| | | 61078 | សោហ៊ុយនិងសំណងផ្សេងៗ | ចំណាយផ្សេងៗ ក្រៅពីអនុគណនីខាងលើ ពាក់ទងនឹងការសិក្សាពិសោធន៍និងចំណាយលើសោហ៊ុយដើម្បីទទួលបាននូវការប្រើប្រាស់សេវានិងសិទ្ធិ និងសំណងផ្សេងៗ ដែលមិនពាក់ទងនឹងការងារវិនិយោគ។ |
| | 6108 | | សោហ៊ុយដឹកជញ្ជូន | ចំណាយលើសោហ៊ុយដឹកជញ្ជូន ដែលផ្តល់ដោយសហគ្រាស និងក្រុមហ៊ុនជានីតិបុគ្គលនិងរូបវន្តបុគ្គល។ |
| | | 61081 | សម្ភារ និងទំនិញ | ចំណាយលើការដឹកជញ្ជូនសម្ភារ និងទំនិញ ដូចជា៖ ការដឹកជញ្ជូនហិបកាទូត, គេសទំនិញ, ថ្នាំពេទ្យ, សម្ភារការិយាល័យ, សម្ភារបរិក្ខារ, បច្ចេកទេសស្នារឹម។ល។ |
| | | 61088 | សោហ៊ុយដឹកជញ្ជូនផ្សេងៗ | ចំណាយលើការដឹកជញ្ជូនផ្សេងៗ។ |
| | 6109 | | បុគ្គលិកខាងក្រៅ | ចំណាយលើការជួលបុគ្គលិកពីខាងក្រៅដែលមិនមែនជាមន្ត្រីរាជការ។ |
| | | 61091 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា | ចំណាយលើការជួលទីប្រឹក្សា និងអ្នកជំនួយការជាជនជាតិខ្មែរ និងបុគ្គលិកជាប់កិច្ចសន្យា ដែលជ្រើសរើសដោយក្រសួង ស្ថាប័នផ្ទាល់។ |
| | | 61092 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា | ចំណាយលើការជួលទីប្រឹក្សា និងអ្នកជំនួយការជាជនជាតិបរទេស។ |
| | | 61093 | បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ | ចំណាយលើបុគ្គលិក-សមូហភាពសាធារណៈផ្សេងៗទៀត ដែលមិនមែនជាមន្ត្រីរាជការ ដូចជា៖ ចំណាយលើប្រាក់ឧបត្ថម្ភដល់គ្រូមត្តេយ្យសហគមន៍ និងបុគ្គលិកឃុំ ដែលដឹកក្មេងៗទៅសាលា, សហគមន៍, ភូមិ, ឃុំ។ល។ |
| | | 61094 | ប្រាក់វិភាជន៍សង្គមសម្រាប់បុគ្គលិកខាងក្រៅ | ចំណាយប្រាក់ឧបត្ថម្ភវិភាជន៍សង្គមសម្រាប់បុគ្គលិកខាងក្រៅ។ល។ |
| | | 61098 | បុគ្គលិកខាងក្រៅផ្សេងៗ | ចំណាយលើបុគ្គលិកខាងក្រៅផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6110 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | ចំណាយលើសោហ៊ុយទទួលភ្ញៀវ, ប្រជុំ, សិក្ខាសាលា, សន្និសីទ, ពិធីបុណ្យ, ពិធីតាំងពិពណ៌ក្នុងនិងក្រៅប្រទេសចំណាយលើ [illegible] អនុស្សាវរីយ៍នៅក្នុងនិងក្រៅប្រទេស និងការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ។ |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | ចំណាយដែលពាក់ព័ន្ធនឹងការទទួលភ្ញៀវជាតិ ដូចជា៖ តែ, កាហ្វេ, ទឹកក្រូច, ស្ករ, នំ, ផ្លែឈើ ។ល។ និងចំណាយផ្សេងៗ [illegible] ពាក់ទងនឹងការរៀបចំពិធីជប់លៀងក្នុងការទទួលភ្ញៀវ លើកលែងតែចំណាយលើសោហ៊ុយបេសកកម្មក្នុងប្រទេសដែលត្រូវកត់ត្រាចូលក្នុងគណនី [illegible] |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | ចំណាយដែលពាក់ព័ន្ធនឹងការទទួលភ្ញៀវបរទេស ដូចជា៖ តែ, កាហ្វេ, ទឹកក្រូច, ស្ករ, នំ, ផ្លែឈើ ។ល។ និងចំណាយផ្សេងៗទៀត ដែលទាក់ទងនឹងការរៀបចំពិធីជប់លៀងក្នុងការទទួលភ្ញៀវ លើកលែងតែចំណាយលើសោហ៊ុយបេសកកម្មក្នុងប្រទេសដែលត្រូវកត់ត្រាចូលក្នុងគណនីលេខ ៦១១៣។ |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | ចំណាយលើការប្រជុំ, សិក្ខាសាលា, សម្ពោធសមិទ្ធិផល, សន្និសីទ, សន្និបាត ដូចជា៖ ការរៀបចំឯកសារនិងសម្ភារផ្សេងៗ ការជួលទីតាំងនិងការ-រៀបចំទីកន្លែង, អាហារ, ការឧបត្ថម្ភគ្រូឧទ្ទេសនិងអ្នកសម្របសម្រួល, សន្តិសុខ, និងចំណាយផ្សេងៗ។ ករណីការសិក្ខាសាលាដែលតម្រូវឱ្យមានបេសកកម្ម ត្រូវប្រើគណនី ៦១១២ សម្រាប់ទូទាត់ចំណាយសោហ៊ុយបេសកកម្មក្នុងប្រទេស និងគណនី៦១១៣ សម្រាប់ទូទាត់ចំណាយសោហ៊ុយបេសកកម្មក្រៅប្រទេស។ ចំណាយលើការប្រជុំ, សិក្ខាសាលា, សម្ពោធសមិទ្ធិផល, សន្និសីទ, សន្និបាត ដូចជា៖ ឯកសារ, សម្ភាររៀបចំទីតាំង, អាហារ, សន្តិសុខ, និងការឧបត្ថម្ភផ្សេងៗ។ |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | ចំណាយលើការរៀបចំពិធីបុណ្យជាតិ បុណ្យប្រពៃណី បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ បុណ្យរុក្ខទិវា និងពិធីបុណ្យផ្សេងៗទៀត។ |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស | ចំណាយលើការទិញវត្ថុអនុស្សាវរីយ៍សម្រាប់ជូនភ្ញៀវក្នុងនិងក្រៅប្រទេស ដូចជា៖ ផ្តិល, ថាស, រូបចម្លាក់, គំនូរ។ល។ |
| | | 61106 | ចំណាយសម្រាប់ការតាំងពិពណ៌ នៅក្នុងនិងក្រៅប្រទេស | ចំណាយដែលពាក់ព័ន្ធនឹងការរៀបចំតាំងពិពណ៌នៅក្នុងនិងក្រៅប្រទេស លើកលែងតែចំណាយលើសោហ៊ុយបេសកកម្ម ដែលត្រូវប្រើគណនី ៦១១២ សម្រាប់ទូទាត់ចំណាយសោហ៊ុយបេសកកម្មក្នុងប្រទេស និងគណនី៦១១៣ សម្រាប់ទូទាត់ចំណាយសោហ៊ុយបេសកកម្មក្រៅប្រទេស។ |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | ចំណាយលើការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ តាមរយៈ ផ្ទាំងប៉ាណូ, ផ្ទាំងព័ត៌មានសម្រាប់ផ្សព្វផ្សាយ, ស្បតផ្សព្វផ្សាយតាម-វិទ្យុ, ទូរទស្សន៍។ល។ |
| | | 61108 | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយផ្សេងៗ | ចំណាយលើការទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6111 | | សារព័ត៌មាន និងឯកសារ | ចំណាយលើការជាវសារព័ត៌មាន និងទស្សនាវដ្តីជាប្រចាំ សៀវភៅរាជកិច្ច និងឯកសារផ្សេងៗទៀត។ |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | ចំណាយលើការជាវសារព័ត៌មានជាប្រចាំ។ |
| | | 61112 | ចំណាយលើការជាវទស្សនាវដ្តី | ចំណាយលើការជាវទស្សនាវដ្តីជាប្រចាំ។ |
| | | 61113 | ចំណាយលើការជាវសៀវភៅរាជកិច្ច | ចំណាយលើការជាវសៀវភៅរាជកិច្ច។ |
| | | 61118 | ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ | ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6112 | | សោហ៊ុយបេសកកម្មក្នុងប្រទេស | ចំណាយលើប្រាក់បេសកកម្ម និងសោហ៊ុយធ្វើដំណើរនិងស្នាក់នៅរបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដែលត្រូវបំពេញបេសកកម្មក្នុងប្រទេស ដោយយោបកំណត់របស់អនុក្រឹត្យ។ |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | ចំណាយលើសោហ៊ុយធ្វើដំណើរសម្រាប់ចុះបំពេញបេសកកម្មនៅក្នុងប្រទេស ដូចជា៖ ទិញសំបុត្រឡាន, យន្តហោះ, កប៉ាល់។ល។ |
| | | 61122 | សោហ៊ុយបេសកកម្ម | ចំណាយលើរបបប្រាក់បេសកកម្មក្នុងប្រទេស។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 61123 | សោហ៊ុយស្នាក់នៅ | ចំណាយលើការស្នាក់នៅ និងហូបចុក របស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដែលត្រូវចុះបេសកកម្មក្នុងប្រទេស។ |
| | | 61128 | សោហ៊ុយក្នុងប្រទេសផ្សេងៗ | ចំណាយលើសោហ៊ុយបេសកកម្មក្នុងប្រទេសផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6113 | | សោហ៊ុយបេសកកម្មក្រៅប្រទេស | ចំណាយលើប្រាក់បេសកកម្ម និងសោហ៊ុយធ្វើដំណើរនិងស្នាក់នៅរបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដែលត្រូវបំពេញបេសកកម្មក្រៅប្រទេស ដោយរបបកំណត់របស់អនុក្រឹត្យ។ |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | ចំណាយលើសោហ៊ុយធ្វើដំណើរសម្រាប់ចុះបំពេញបេសកកម្មក្រៅប្រទេស ដូចជា៖ ទិញសំបុត្រយន្តហោះ, យន្តហោះ, កប៉ាល់, បង់ពន្ធព្រលាន។ល។ |
| | | 61132 | សោហ៊ុយបេសកកម្ម | ចំណាយលើរបបប្រាក់បេសកកម្មក្រៅប្រទេស។ |
| | | 61133 | សោហ៊ុយស្នាក់នៅ | ចំណាយលើការស្នាក់នៅ និងហូបចុករបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដែលត្រូវចុះបេសកកម្មក្រៅប្រទេស។ |
| | | 61138 | សោហ៊ុយក្រៅប្រទេសផ្សេងៗ | ចំណាយលើសោហ៊ុយបេសកកម្មក្រៅប្រទេសផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6114 | | សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ | ចំណាយលើការផ្ញើឯកសារ និងទំនិញផ្សេងៗ តាមប្រៃសណីយ៍ និងចំណាយលើការប្រើប្រាស់សេវា ទូរស័ព្ទ ទូរសារ និងសេវាអ៊ីនធឺណិត។ល។ |
| | · | 61141 | សោហ៊ុយប្រៃសណីយ៍ | ចំណាយលើសោហ៊ុយប្រៃសណីយ៍ ដូចជា៖ ការផ្ញើឯកសារ, កញ្ចប់ឥវ៉ាន់។ល។ |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | ចំណាយលើសោហ៊ុយទូរគមនាគមន៍ ដូចជា៖ការប្រើប្រាស់សេវាទូរស័ព្ទ, ទូរសារ, និងសេវាអ៊ីនធឺណិត។ល។ |
| | | 61148 | សោហ៊ុយទូរគមនាគមន៍ផ្សេងៗ | ចំណាយលើសោហ៊ុយទូរគមនាគមន៍ ផ្សេងៗ ក្រៅពីអនុគណនីខាងលើ។ |
| | 6115 | | សោហ៊ុយធនាគារ | ចំណាយលើសោហ៊ុយសម្រាប់សេវាធនាគារជាតិ ធនាគារពាណិជ្ជ ដូចជា៖សោហ៊ុយលើការបង់ចំណូលជារូបិយប័ណ្ណ, កម្រៃជើងសារ លើការទិញមូលប័ត្រ, និងភាគហ៊ុន។ល។ |
| | | 61151 | សោហ៊ុយធនាគារ | ចំណាយលើសោហ៊ុយសម្រាប់សេវាធនាគារជាតិ ធនាគារពាណិជ្ជ ដូចជា៖សោហ៊ុយលើការបង់ចំណូលជារូបិយប័ណ្ណ, កម្រៃជើងសារ លើការទិញមូលប័ត្រ និងភាគហ៊ុន។ល។ |
| | 6116 | | សំណងកិច្ចសន្យា | ចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្តល់ឱ្យក្រុមហ៊ុននីតិបុគ្គល រូបវន្តបុគ្គលជាថ្នូរនឹងការរំលាយ កិច្ចសន្យាមុនកាលកំណត់។ |
| | | 61161 | ផ្លូវថ្នល់ ផ្លូវទឹក | ចំណាយសំណងកិច្ចសន្យាលើការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដូចជា៖ ផ្លូវថយន្ត, ផ្លូវថ្មើរជើង, ស្ពាន, ប្រព័ន្ធ[illegible] រំដោះទឹក, ការងារជួសជុលជើងទេរផ្លូវថ្នល់, ការជីកកាត់ភ្នំ, ការជីករូងភ្នំ, ការបំពាក់សម្ភារ, បរិក្ខារផ្លូវថ្នល់ ស្ពាន, ការ[illegible] ការពារភាពអន្តរាយនៃទ្រព្យសម្បត្តិផ្លូវថ្នល់ រួមទាំងចំណាយលើការសិក្សា និងពិសោធន៍ និងការត្រួតពិនិត្យគម្រោងជួ[illegible] សម្ព័ន្ធខាងលើ។ ចំណាយលើការជួសជុល និង ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ដូចជា៖ ផែ និងជួសជុលផ្លូវនាវាចរណ៍ [illegible] ផែ រួមទាំងចំណាយលើការសិក្សា និងពិសោធន៍ និងការត្រួតពិនិត្យគម្រោងការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធខាងលើ។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 61162 | ធារាសាស្ត្រ | ចំណាយសំណង់កិច្ចសន្យាលើការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រដូចជា÷ អាងស្តុកទឹក, ប្រឡាយ, ទំនប់, ព្រែកជីក, សំណង់សិល្បការ និងការជីកស្រះ, ការជួសជុល និងថែទាំច្រាំងទន្លេ, ការជីក ឬ បូមស្តារបឹង ស្ទឹង អូរ ព្រែក និង ប្រព័ន្ធបង្ហូរទឹកធម្មជាតិប្រហាក់ប្រហែល សាងសង់ស្ថានីយ៍បូមទឹក និងទិញម៉ាស៊ីនបូមទឹក រួមទាំងចំណាយលើការសិក្សា ពិសោធន៍ និងការត្រួតពិនិត្យគម្រោងការជួសជុល និង ថែទាំហេដ្ឋារចនាសម្ព័ន្ធខាងលើ។ |
| | | 61163 | អាយស្ម័យយាន | ចំណាយសំណង់កិច្ចសន្យាលើការជួសជុល និងថែទាំអាយស្ម័យយាន និងលើការសាងសង់ផ្សេងៗទៀតដែលបម្រើឱ្យអាយស្ម័យយាន ដូចជា÷ ផ្លូវដែក, ព្រែកជីកសម្រាប់រថភ្លើងឆ្លងកាត់ រួមទាំងចំណាយលើការសិក្សា និងពិសោធន៍ និងការត្រួតពិនិត្យគម្រោង។ |
| | | 61164 | អាកាសយានដ្ឋាន | ចំណាយសំណង់កិច្ចសន្យាលើការជួសជុល និងថែទាំអាកាសយានដ្ឋាន និងលើការសាងសង់ផ្សេងៗទៀតដែលបម្រើឱ្យអាកាសយានដ្ឋាន ដូចជា÷ កន្លែងចុះចតយន្តហោះ រួមទាំងចំណាយលើការសិក្សា និងពិសោធន៍ និងការត្រួតពិនិត្យគម្រោង។ |
| | | 61165 | ទូរគមនាគមន៍ | ចំណាយសំណង់កិច្ចសន្យាលើការជួសជុល និងថែទាំប្រព័ន្ធទូរគមនាគមន៍ ដូចជា÷ ខ្សែទូរគមនាគមន៍, អង់តែនសម្រាប់ទទួលផ្សាយរលក, ខ្សែ-កាប រួមទាំងចំណាយលើការសិក្សា និងពិសោធន៍ និងការត្រួតពិនិត្យគម្រោង។ |
| | | 61166 | អគ្គិសនី | ចំណាយសំណង់កិច្ចសន្យាលើការជួសជុល និង ថែទាំរោងចក្រអគ្គិសនី និងចំណាយផ្សេងៗទៀតដើម្បីបម្រើឱ្យការងារអគ្គិសនី ដូចជា÷ខ្សែភ្លើង ទប់អគ្គិសនី ភ្លើងតង់ស្យុងខ្ពស់ រួមទាំងចំណាយលើការសិក្សា និងពិសោធន៍ និងការត្រួតពិនិត្យគម្រោង។ |
| | | 61167 | បណ្តាញបង្ហូរទឹក និងអនាម័យ | ចំណាយសំណង់កិច្ចសន្យាលើការជួសជុល និង ថែទាំបណ្តាញបង្ហូរទឹកដូចជា÷ ការដាក់ប្រព័ន្ធលូបង្ហូរទឹកកខ្វក់, ការជីកអាងស្តុកទឹក សម្រាប់ការធ្វើបន្សុតទឹកកខ្វក់ រួមទាំងចំណាយលើការសិក្សា និងពិសោធន៍ និងការត្រួតពិនិត្យគម្រោង។ |
| | | 61168 | ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | ចំណាយសំណង់កិច្ចសន្យាលើការជួសជុល និង ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ ដូចជា÷ ពហុកីឡាដ្ឋាន, បញ្ជរមណ្ឌលកំសាន្ត, លូទឹកស្អុយ, អណ្តូង, និងកន្លែងធ្វើអាជីវកម្មស្រទាប់ប៉ែនៅក្រោមដី។ |
| | 6198 | | សេវាកម្មផ្សេងៗទៀត | ចំណាយសេវាកម្មផ្សេងៗទៀត ក្រៅពីគណនីខាងលើ។ |
| | | 61981 | សេវាកម្មផ្សេងៗទៀត | ចំណាយលើសេវាកម្មផ្សេងៗទៀត ក្រៅពីគណនីខាងលើ។ |
| 64 | | | បន្ទុកបុគ្គលិក | ជំពូកនេះកត់ត្រាចំណាយលើបន្ទុកបុគ្គលិក ដូចជា÷ លាភការនិងប្រាក់បំណាច់ នៃអំណាចសាធារណៈ; អំណាចរដ្ឋបាលថ្នាក់ក្រោមជាតិ [illegible] បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍, បុគ្គលិកមិនមែនក្របខ័ណ្ឌដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ, ប្រាក់វិភាជន៍សង្គម [illegible] គ្រួសារមន្ត្រីរាជការ, និងបន្ទុកបុគ្គលិកផ្សេងៗទៀត។ |
| | 6401 | | លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ | ចំណាយលើការផ្តល់លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ។ |
| | | 64011 | ខុទ្ទកាល័យព្រះបរមរាជវាំង | ចំណាយលើប្រាក់បៀវត្សរបស់ព្រះមហាក្សត្រ និងចំណាយលើការទទួលភ្ញៀវ និងចំណាយរៀបចំតុបតែងជាប្រយោជន៍ដល់ព្រះមហាក្សត្រ។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាគណនី |
| --- | --- | --- | --- | --- |
| | | 64012 | ប្រាក់បំណាច់ ប្រធាន អនុប្រធាន និងសមាជិកស្ថាប័នកំពូល | ចំណាយលើប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗទៀត ជូនប្រធាន, អនុប្រធាន, និងសមាជិកព្រឹទ្ធសភា រដ្ឋសភាជាតិ និងក្រុមប្រឹក្សាពម្មនុញ្ញ។ |
| | | 64013 | ប្រាក់បំណាច់ នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី | ចំណាយលើប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗទៀត ជូននាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី។ |
| | | 64014 | ប្រាក់បំណាច់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ | ចំណាយលើប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗទៀតជូនរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ។ |
| | | 64015 | ប្រាក់បំណាច់អង្គទូត | ចំណាយលើប្រាក់បំណាច់ជូនមន្ត្រីអង្គទូត។ |
| | | 64016 | លាភការទីប្រឹក្សា | ចំណាយលើការផ្តល់លាភការជូនទីប្រឹក្សាដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ។ |
| | | 64017 | លាភការបេសកជន | ចំណាយលើការផ្តល់លាភការជូនបេសកជនដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ។ |
| | | 64018 | លាភការអ្នកជំនួយការ | ចំណាយលើការផ្តល់លាភការជូនអ្នកជំនួយការដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ។ |
| | 6402 | | លាភការនិងប្រាក់បំណាច់ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ | ចំណាយលើការផ្តល់លាភការ និងប្រាក់បំណាច់ជូនបុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ដែលកំពុងបម្រើការងារក្នុងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 64021 | បៀវត្សមូលដ្ឋាន | ចំណាយលើបៀវត្សមូលដ្ឋាន ដោយគិតទៅតាមប្រភេទកាំប្រាក់ និងទៅតាមតម្លៃសន្ទស្សន៍របស់ប្រភេទកាំប្រាក់។ |
| | | 64022 | ប្រាក់បំណាច់មុខងារ | ចំណាយលើប្រាក់បំណាច់មុខងារ ដោយគិតទៅតាមមុខងារ និងទៅតាមអតីតភាពការងារនៃមុខងារ។ |
| | | 64023 | ប្រាក់បំណាច់ម៉ោងបន្ថែម | ចំណាយលើប្រាក់បំណាច់ម៉ោងបន្ថែមជូនមន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ ដែលបានធ្វើការងារលើសម៉ោង។ |
| | | 64024 | ប្រាក់កំរៃតុរកោសល្យ | ចំណាយលើប្រាក់កំរៃតុរកោសល្យជូនមន្ត្រី និងគ្រូបង្រៀន។ |
| | | 64025 | ប្រាក់បំប៉នជីវភាពពិសេស | ចំណាយលើប្រាក់បំប៉នជីវភាពពិសេស។ |
| | | 64026 | ប្រាក់បំណាច់តំបន់ | ចំណាយឧបត្ថម្ភដល់មន្ត្រីរាជការ ប៉ូលីស និងទាហាន ដែលទៅធ្វើការនៅកន្លែងឆ្ងាយពីលំនៅដ្ឋានអចិន្ត្រៃយ៍។ |
| | | 64027 | ប្រាក់បំណាច់ទទួលខុសត្រូវ | ចំណាយឧបត្ថម្ភដល់មន្ត្រីរាជការ ប៉ូលីស និងទាហាន ដែលបំពេញភារៈកិច្ចតាមការចាត់តាំងរបស់ក្រសួង-ស្ថាប័ន បន្ថែមលើមុខងារ និងភារៈកិច្ចរបស់ខ្លួន។ |
| | | 64028 | ប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព | ចំណាយលើប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព ដូចជា÷មន្ត្រីដែលបានចាត់ឱ្យទៅបំពេញការងារនៅតំបន់ដែលមានគ្រោះថ្នាក់ ភពគ្រាត 'មន្ត្រីធ្វើការងារនៅក្នុងមន្ទីរពិសោធន៍ ពេទ្យក្រពីមី។ល។ |
| | 6403 | | ប្រាក់បំណាច់ផ្សេងៗ | ចំណាយលើរង្វាន់ និងប្រាក់បំណាច់ផ្សេងៗ ជូនបុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ |
| | | 64033 | រង្វាន់ | ចំណាយលើការផ្តល់រង្វាន់ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ជូនមន្ត្រីរាជការ។ |
| | | 64034 | ប្រាក់បំណាច់បុគ្គលិកអង្គភាពផ្សេងៗ | ចំណាយឧបត្ថម្ភជូនមន្ត្រីរាជការ, ប៉ូលីស, ទាហាន, និងមន្ត្រីជាប់កិច្ចសន្យា មកពីស្ថាប័នផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដែលចូលរួមរៀបចំពិធីផ្សេងៗ ដូចជា÷ ការប្រឡងសញ្ញាប័ត្រ, ការប្រកួតកីឡា, ការទទួលភ្ញៀវ។ល។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាចំណាយ |
|---|---|---|---|---|
| | | 64035 | ប្រាក់បំណាច់ប្រូបង្គោលអង្គភាពផ្សេងៗ | ការចំណាយលើប្រាក់បំណាច់គ្រូបង្គោលដែលជាបុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ និងបុគ្គលិកមិនមែនក្របខ័ណ្ឌដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈមកពីអង្គភាពផ្សេងៗ។ |
| | | 64037 | ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់អង្គភាពដទៃទៀត | ចំណាយប្រាក់ឧបត្ថម្ភជូនសមាជិកក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពដទៃទៀត |
| | | 64038 | ប្រាក់បំណាច់ផ្សេងៗ | ប្រាក់បំណាច់ផ្សេងៗទៀតក្រៅពីអនុគណនីខាងលើ ដូចជា៖ ចំណាយឧបត្ថម្ភអ្នកនិពន្ធ, អ្នកបកប្រែ, អ្នកផ្ទៀងផ្ទាត់, អ្នករៀបចំចងក្រងឯកសារ, អ្នកសរសេរសញ្ញាប័ត្រ, អ្នកវាយកុំព្យូទ័រ, អ្នកឈ្លបៗល។ |
| | 6404 | | លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ | ចំណាយលើការផ្តល់លាភការ និងប្រាក់បំណាច់ ជូនមន្ត្រីជាប់កិច្ចសន្យា។ |
| | | 64041 | បៀវត្សមូលដ្ឋាន បុគ្គលិកជាប់កិច្ចសន្យា | ចំណាយជាបៀវត្ស ជូនមន្ត្រីជាប់កិច្ចសន្យា។ |
| | | 64042 | លាភការផ្សេងៗទៀត បុគ្គលិកជាប់កិច្ចសន្យា | ចំណាយជាលាភការផ្សេងៗទៀត ជូនបុគ្គលិកជាប់កិច្ចសន្យា ដែលមានគុណសម្បត្តិ ដូចជា៖ ប្រាក់លើកទឹកចិត្ត។ |
| | | 64048 | លាភការផ្សេងៗ | ចំណាយឧបត្ថម្ភផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6405 | | ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ | ចំណាយលើប្រាក់វិភាជន៍សង្គមផ្សេងៗ ដូចជា៖ឧបត្ថម្ភមន្ត្រីមានជម្ងឺ, អ្នកសម្រាលកូន, មរណភាព, និវត្តជន, អ្នកសុំឈប់ពីការងារ, គ្រោះថ្នាក់ក្នុងការងារ និងពិការភាព, និងប្រាក់វិភាជន៍សង្គមផ្សេងៗទៀតសម្រាប់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ និងមន្ត្រីជាប់កិច្ចសន្យាដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ។ |
| | | 64051 | មន្ត្រីមានជម្ងឺ | ចំណាយឧបត្ថម្ភដល់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ និងមន្ត្រីមិនមែនក្របខ័ណ្ឌដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ ដែលមានជម្ងឺ។ |
| | | 64052 | អ្នកសម្រាលកូន | ចំណាយឧបត្ថម្ភដល់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ និងមន្ត្រីជាប់កិច្ចសន្យា ដែលសម្រាលកូន។ |
| | | 64053 | មរណភាព | ចំណាយឧបត្ថម្ភដល់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ និងមន្ត្រីជាប់កិច្ចសន្យា ដែលទទួលមរណភាព។ |
| | | 64054 | ឧបត្ថម្ភនិវត្តជន | ចំណាយឧបត្ថម្ភដល់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ដែលចូលនិវត្តន៍។ |
| | | 64055 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | ចំណាយឧបត្ថម្ភដល់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ដែលលាឈប់ពីការងារ។ |
| | | 64056 | គ្រោះថ្នាក់ក្នុងការងារនិងពិការភាព | ចំណាយឧបត្ថម្ភដល់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ និងមន្ត្រីជាប់កិច្ចសន្យាដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ ដែលជួបគ្រោះថ្នាក់ក្នុង ពេលបំពេញភារកិច្ច។ |
| | | 64058 | ប្រាក់វិភាជន៍សង្គមផ្សេងៗទៀតសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ | ចំណាយឧបត្ថម្ភផ្សេងៗទៀត ដល់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ និងមន្ត្រីជាប់កិច្ចសន្យាដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ ក្រៅពី អនុគណនីខាងលើ។ |
| | 6406 | | ប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ | ចំណាយឧបត្ថម្ភកូននិងប្រពន្ធរបស់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍។ |
| | | 64061 | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | ចំណាយឧបត្ថម្ភកូនរបស់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ដែលមានអាយុចាប់ពី២០ឆ្នាំចុះក្រោម។ |

| ជំពូក | គណនី | អនុគណនី | ចរិយាយ | សេចក្តីពន្យល់ពីមាតិកាជំពូក |
|---|---|---|---|---|
| | | 64063 | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | ចំណាយឧបត្ថម្ភប្រពន្ធ ឬ ប្តី របស់មន្ត្រីរាជការ។ |
| | | 64064 | ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ | ចំណាយឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍។ |
| | | 64068 | ប្រាក់វិភាជន៍សង្គមផ្សេងៗទៀតសម្រាប់គ្រួសារមន្ត្រីរាជការ | ចំណាយឧបត្ថម្ភផ្សេងៗទៀត ដល់កូននិងប្រពន្ធរបស់មន្ត្រីក្របខ័ណ្ឌអចិន្ត្រៃយ៍ ក្រៅពីអនុគណនីខាងលើ។ |
| | 6407 | | លាភការ និងប្រាក់បំណាច់នៃអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិ | ចំណាយលើលាភការ និងប្រាក់បំណាច់នៃអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 64071 | ប្រាក់បំណាច់អភិបាល (រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ) | ចំណាយលើប្រាក់បំណាច់មុខងារជូនអភិបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ។ |
| | | 64072 | ប្រាក់បំណាច់អភិបាលរង (រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ) | ចំណាយលើប្រាក់បំណាច់មុខងារជូនអភិបាលរង រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ។ |
| | | 64073 | ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សា (រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់) | ចំណាយប្រាក់ឧបត្ថម្ភជូនសមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់។ |
| | | 64074 | ប្រាក់ឧបត្ថម្ភមន្ត្រីភូមិ | ចំណាយលើប្រាក់ឧបត្ថម្ភប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ។ |
| | | 64075 | លាភការទីប្រឹក្សា | ចំណាយលើការផ្តល់លាភការជូនទីប្រឹក្សាដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ។ |
| | | 64076 | លាភការបេសកជន | ចំណាយលើការផ្តល់លាភការជូនបេសកជនដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ។ |
| | | 64077 | លាភការអ្នកជំនួយការ | ចំណាយលើការផ្តល់លាភការជូនអ្នកជំនួយការដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ។ |
| | | 64078 | ប្រាក់បំណាច់ផ្សេងៗទៀត | ចំណាយលើប្រាក់បំណាច់ផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6498 | | បន្ទុកបុគ្គលិកផ្សេងៗទៀត | ចំណាយលើបន្ទុកបុគ្គលិកផ្សេងៗទៀត ក្រៅពីគណនីខាងលើ។ |
| | | 64981 | បន្ទុកបុគ្គលិកផ្សេងៗទៀត | ចំណាយលើបន្ទុកបុគ្គលិកផ្សេងៗទៀត ក្រៅពីគណនីខាងលើ។ |
| | | | **ប្រភេទទី២ : បន្ទុកហិរញ្ញវត្ថុ** | គឺជាចំណាយដែលទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ។ |
| 66 | | | **បន្ទុកហិរញ្ញវត្ថុ** | ជំពូកនេះកត់ត្រាចំណាយលើការប្រាក់នៃបំណុលការខ្ចីក្នុងប្រទេស និងការប្រាក់នៃបំណុលក្រៅប្រទេស និងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត និងការប្រាក់សម្រាប់ការបោះផ្សាយប័ណ្ណរតនាគារ និងសញ្ញាប័ណ្ណផ្សេងៗ។ ចំណែកឯ បន្ទុកដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ នៅក្នុងការអនុវត្តសេវាធនាគារ ត្រូវបានកត់ត្រានៅក្នុងគណនី ៦១១៥ "សោហ៊ុយធនាគារ"។ រីឯការសងវិញនូវប្រាក់ដើមនៃការខ្ចី ត្រូវកត់ត្រានៅក្នុងចំណាយជាមូលធនជំពូក ៥០ "ការខ្ចី"។ ចំពោះលម្អៀងនៃការប្តូរប្រាក់ត្រូវបានចាត់ទុកជាការខាតបង់ពីការធ្វើប្រតិបត្តិការហិរញ្ញវត្ថុជារូបិយប័ណ្ណ។ |
| | 6601 | | ការប្រាក់នៃបំណុលក្នុងប្រទេស | ចំណាយលើការប្រាក់នៃការខ្ចីក្នុងប្រទេស និងចំណាយលើការប្រាក់សម្រាប់ការបោះផ្សាយប័ណ្ណរតនាគារ និងសញ្ញាប័ណ្ណផ្សេងៗ។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 66011 | ធនាគារជាតិនៃកម្ពុជា | ចំណាយលើការប្រាក់នៃការខ្ចីពីធនាគារជាតិនៃកម្ពុជា។ |
| | | 66012 | ធនាគារពាណិជ្ជ | ចំណាយលើការប្រាក់នៃការខ្ចីពីធនាគារពាណិជ្ជ។ |
| | | 66013 | ប័ណ្ណរតនាគារ | ចំណាយលើការប្រាក់នៃការបោះផ្សាយប័ណ្ណរតនាគារ។ |
| | | 66014 | សញ្ញាប័ណ្ណ | ចំណាយលើការប្រាក់នៃការបោះផ្សាយសញ្ញាប័ណ្ណ។ |
| | | 66018 | ផ្សេងៗ | ចំណាយលើការប្រាក់ផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6602 | | ការប្រាក់នៃបំណុលក្រៅប្រទេស | ចំណាយលើការប្រាក់នៃការខ្ចីក្រៅប្រទេសពីពហុភាគី និងទ្វេភាគី។ |
| | | 66021 | ពហុភាគី | ចំណាយលើការប្រាក់នៃការខ្ចីក្រៅប្រទេសពីពហុភាគី ដូចជា៖ ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, និងអង្គការអន្តរជាតិផ្សេងៗទៀត។ |
| | | 66022 | ទ្វេភាគី | ចំណាយលើការប្រាក់នៃការខ្ចីក្រៅប្រទេសពីទ្វេភាគី ដូចជា៖ ប្រទេសចិន, ជប៉ុន, បារាំង, អាល្លឺម៉ង់, និងប្រទេសផ្សេងៗទៀត។ |
| | 6698 | | បន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត | ចំណាយលើបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត ក្រៅពីគណនីខាងលើ។ |
| | | 66981 | ខាតពីការប្ដូរប្រាក់ | ចំណាយលើភាពលម្អៀងនៃអត្រាប្ដូរប្រាក់។ |
| | | 66988 | បន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត | ចំណាយលើបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត។ |
| | | | **ប្រភេទទី៣ : អន្តរាគមន៍សាធារណៈ** | ចំណាយសម្រាប់អត្ថប្រយោជន៍សង្គម, ឧបត្ថម្ភកធន, និងជំនួយសង្គម។ |
| 62 | | | **អត្ថប្រយោជន៍សង្គម** | ចំណាយលើការផ្ដល់អត្ថប្រយោជន៍សង្គម មានដូចជា៖ អត្ថប្រយោជន៍សន្តិសុខសង្គម, ជំនួយសង្គមដល់ប្រជាពលរដ្ឋ, ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គមនិងវប្បធម៌, ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ, ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច និងចំណាយលើអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។ |
| | 6201 | | អត្ថប្រយោជន៍សន្តិសុខសង្គម | ជាអត្ថប្រយោជន៍ហិរញ្ញវត្ថុដែលបានទទួលដោយកម្មករដែលបានចូលនិវត្តន៍ ដែលបានបង់ប្រាក់ចូលទៅក្នុងប្រព័ន្ធសន្តិសុខសង្គមក្នុងអំឡុងពេលធ្វើការរបស់គេ។ |
| | | 62011 | អត្ថប្រយោជន៍សន្តិសុខសង្គម | ជាអត្ថប្រយោជន៍ហិរញ្ញវត្ថុដែលបានទទួលដោយកម្មករដែលបានចូលនិវត្តន៍ ដែលបានបង់ប្រាក់ចូលទៅក្នុងប្រព័ន្ធសន្តិសុខសង្គមក្នុងអំឡុងពេលធ្វើការរបស់គេ។ |
| | 6202 | | ជំនួយសង្គមដល់ប្រជាពលរដ្ឋ | ការផ្ដល់វិភាគទានសង្គមទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ទៅដល់គ្រួសារទាំងមូលឬចំណែកខ្លះនៃប្រជាជន ដែលប្រឈមនឹងហានិភ័យមួយចំនួន ដូចជា៖ ហេតុការណ៍ដែលងាយនឹងទទួលផលវិបាក ទទួលផលប៉ះពាល់ជាអវិជ្ជមាន ខាងផ្នែកសុខភាព ដែលនាំឱ្យកើនឡើងនូវបន្ទុកចំណាយ និងកាត់បន្ថយចំណូលរបស់ប្រជាជន។ |
| | | 62021 | ជំនួយដល់ប្រជាជនក្រីក្រសម្រាកពេទ្យ និងចំណាយដំណើរការ របស់មណ្ឌលថែទាំសុខភាព | ការផ្ដល់វិភាគទានសង្គមទាំងផ្នែកហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ ដល់ប្រជាជនក្រីក្រសម្រាកពេទ្យ និងដល់មណ្ឌលដែលផ្ដល់សេវាសុខភាព ដូចជា៖ ការចំណាយរបស់ស្រុកប្រតិបត្តិនៃក្រសួងសុខាភិបាល ជាដើម។ |
| | | 62022 | ឱសថ | ចំណាយលើការទិញឱសថ ដើម្បីព្យាបាលជម្ងឺដល់ប្រជាជនទូទៅ។ |

| ជំពូក | គណនី | អនុគណនី | ចំណាយ | សេចក្តីពន្យល់ពីហាតិកាថវិកា |
| --- | --- | --- | --- | --- |
| | | 62023 | អាហារនិងសម្ភារៈ (ស្បៀង) | ចំណាយលើការទិញអង្ករសម្រាប់ប្រគល់ជូនកម្មវិធីស្បៀងអាហារពិភពលោក, ចំណាយលើការទិញស្បៀងនិងសម្ភារៈ, សម្រាប់ផ្តល់ជូនប្រជាជនទូទៅ ដែលមិនមែនជាមន្ត្រីរាជការ, ចំណាយលើការទិញស្រូវពូជ, ការទិញស្បៀង។ |
| | | 62024 | ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ | អំណោយជាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ សម្រាប់ជួយដល់ប្រជាជនទូទៅដែលរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិ (ទឹកជំនន់ រញ្ជួយដីគ្រោះរាំងស្ងួត ខ្យល់ព្យុះ ។ល។) ដូចជា÷ ចំណាយឧបត្ថម្ភជនរងគ្រោះ, ចំណាយទិញប្រេង, ស្រូវពូជ, ជីគីមី, ថ្នាំសម្លាប់សត្វល្អិត។ល។ |
| | | 62025 | អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស | អាហារូបករណ៍សម្រាប់ផ្តល់ជូនប្រជាជនទូទៅ, សិស្ស, និងនិស្សិត ដែលមិនមែនជាមន្ត្រីរាជការដើម្បីបំប៉ន និងសិក្សាស្រាវជ្រាវក្នុងប្រទេស។ |
| | | 62026 | អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្រៅប្រទេស | អាហារូបករណ៍សម្រាប់ផ្តល់ជូនប្រជាជនទូទៅ, សិស្ស, និងនិស្សិត ដែលមិនមែនជាមន្ត្រីរាជការ ដើម្បីបំប៉ន និងសិក្សាស្រាវជ្រាវក្រៅប្រទេស ដូចជា÷ ចំណាយបង់សិទ្ធិប្រឡង,ចំណាយលើសោហ៊ុយធ្វើដំណើរ, ហូបចុក, ស្នាក់នៅ, និងផ្សេងៗទៀតរបស់សិស្ស និស្សិត ដែលត្រូវទៅចូលរួមប្រឡង។ រីឯការចំណាយសម្រាប់ការចូលរួមរបស់មន្ត្រីរាជការ ដែលត្រូវដឹកនាំសិក្ខាកាម, សិស្ស, និស្សិត, ត្រូវកត់ត្រានៅក្នុងគណនី ៦១១៣"សោហ៊ុយបេសកកម្មក្រៅប្រទេស"។ |
| | | 62027 | សំណងខូចខាតដោយសារឧបទ្ទវហេតុសាធារណៈ | ចំណាយសងការខូចខាតដោយឧបទ្ទវហេតុសាធារណៈផ្សេងៗ ដូចជា÷ សំណងខូចខាតក្នុងព្រឹត្តិការណ៍, កូដកម្ម, សំណងខូចខាតដែលបង្កដោយមន្ត្រីមានសមត្ថកិច្ច, នៅក្នុងការបំពេញបេសកកម្ម។ល។ |
| | | 62028 | ជំនួយសង្គមផ្សេងៗទៀត | ចំណាយពិសេសរបស់រាជរដ្ឋាភិបាល ចំណាយអន្តរាគមន៍ និងជំនួយសង្គមផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ ដូចជា÷ ឧបត្ថម្ភដល់ប្រជាជនក្រីក្រ, រង្វាន់សម្រាប់ផ្តល់ជូនកីឡាករ, និងសិស្សដែលទទួលបានជ័យលាភី, ការបង្វិលសងកម្រៃសិក្សា ជួយជនរងគ្រោះដោយអគ្គិភ័យ ។ល។ |
| | 6203 | | ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ | ឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ ហើយមិនស្វែងរកប្រាក់ចំណេញនៅក្នុងការផ្តល់សេវា និងជួយប្រជាជន។ |
| | | 62031 | ឧបត្ថម្ភសហគមន៍ និងរក្សាសណ្តាប់ធ្នាប់ សន្តិសុខសង្គម | ឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដល់សហគមន៍ និងឧបត្ថម្ភកំលាំង ដែលមានភារកិច្ចរក្សាសណ្តាប់ធ្នាប់ សន្តិសុខសង្គម។ |
| | | 62032 | ឧបត្ថម្ភមណ្ឌលកុមារកំព្រា | ឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដល់មណ្ឌលកុមារកំព្រានៅក្នុងការជួយចិញ្ចឹម និងមើលថែទាំកុមារកំព្រា។ |
| | | 62033 | ឧបត្ថម្ភដំណើរលំហែ និងសិក្សា | ចំណាយទស្សនកិច្ចសិក្សានានាក្នុងប្រទេសសម្រាប់សិស្ស, និស្សិត, និងប្រជាជនទូទៅ ដែលមិនមែនជាមន្ត្រីរាជការ។ |
| | | 62034 | ឧបត្ថម្ភភាពបាទក្រហម | ឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដល់កាកបាទក្រហម។ |
| | | 62035 | ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌ | ឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដល់សហគមន៍ កីឡា និងវប្បធម៌ ដូចជា÷ ប្រាក់ឧបត្ថម្ភក្រុមកីឡាករ, [illegible] រៀបចំទីលានប្រកួត។ល។ |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្តីពន្យល់ពីមាតិកាចំណាយ |
|---|---|---|---|---|
| | | 62036 | ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍ | ឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដល់មណ្ឌលស្តារលទ្ធភាពពលកម្មនីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍ សម្រាប់ដំណើរការការងារ។ |
| | | 62037 | ចំណាយសង្គមកិច្ចរបស់ព្រះមហាក្សត្រ | ចំណាយលើការទិញអំណោយសម្រាប់ព្រះមហាក្សត្រដើម្បីចែកជូនដល់ប្រជាជនក្រីក្រ។ |
| | | 62038 | ឧបត្ថម្ភដល់អង្គភាពផ្សេងៗទៀត | ឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ ផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6204 | | ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធី- ផ្សេងៗ | ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ។ |
| | | 62041 | ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ | ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ ដូចជា៖ ចំណាយបង់ប្រាក់សមាជិកភាពជូនសមាគមន៍ក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់។ល។ |
| | 6205 | | ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច | ចំណាយទាក់ទងនឹងការជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ដូចជា៖ ចំណាយឧបត្ថម្ភគាំទ្រដល់អាជីវកម្ម ដែលមានផលប្រយោជន៍ក្នុងមូលដ្ឋាន ចំណាយគាំទ្រដល់ការរៀបចំផ្សារណាត់ ក្នុងការជួយលើកស្ទួយផលិតផលរបស់មូលដ្ឋាន។ |
| | | 62051 | ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច | ចំណាយទាក់ទងនឹងការជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ដូចជា៖ ចំណាយឧបត្ថម្ភគាំទ្រដល់អាជីវកម្ម ដែលមានផលប្រយោជន៍ក្នុងមូលដ្ឋាន ចំណាយគាំទ្រដល់ការរៀបចំផ្សារណាត់ ក្នុងការជួយលើកស្ទួយផលិតផលរបស់មូលដ្ឋាន។ |
| | 6206 | | ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌ | ចំណាយទាក់ទងនឹងការជំរុញកិច្ចការសិក្សា អប់រំ ដូចជា៖ ចំណាយឧបត្ថម្ភគាំទ្រដល់គណៈកម្មាការប្រឡង (ប្រកួត) ឬ ក្រុមការងារ ដែលមិនមែនជាមន្ត្រីរាជការ ឬ ពុំមានថវិកាពីក្រសួងមុខងារសាធារណៈ និងចំណាយផ្សេងៗទៀត ដែលមានផលប្រយោជន៍ក្នុងលើកកម្ពស់ការងារពាក់ព័ន្ធនឹងផ្នែកសង្គមកិច្ច និងវប្បធម៌។ |
| | | 62061 | ចំណាយលើការប្រឡង-ប្រឡងប្រជែង | ចំណាយលើគណៈកម្មការរៀបចំការប្រឡង រួមទាំងការចំណាយឧបត្ថម្ភផ្សេងៗទៀតនៅក្នុងការប្រឡងជូនបុគ្គលិក ឬ ក្រុមការងារដែលមិនមែនជាមន្ត្រីរាជការ ឬ ពុំមានមានថវិកាពីក្រសួងមុខងារសាធារណៈ លើកលែងតែសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការប្រឡង និងប្រាក់ឧបត្ថម្ភកម្លាំងការពារសុវត្ថិភាពនៅក្នុងការរៀបចំការប្រឡង។ |
| | | 62068 | ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌ផ្សេងៗទៀត | ចំណាយលើអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌ផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6298 | | អត្ថប្រយោជន៍សង្គមផ្សេងទៀត | ចំណាយលើការឧបត្ថម្ភផ្សេងទៀត ក្រៅពីគណនីខាងលើ ដែលមានឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ [illegible] សង្គមផ្សេងៗទៀតដូចជា៖ ឧបត្ថម្ភការប្រជុំគណៈបញ្ជាការឯកភាព, ឧបត្ថម្ភការប្រឆាំងគ្រឿងញៀន, និងឧបត្ថម្ភ[illegible]ភូមិ-ឃុំមានសុវត្ថិ-ភាព។ល។ |
| | | 62981 | អត្ថប្រយោជន៍សង្គមផ្សេងទៀត | ចំណាយលើការឧបត្ថម្ភផ្សេងទៀត ក្រៅពីអនុគណនីខាងលើ ដែលមានឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែន[illegible]ហិរញ្ញវត្ថុ[illegible] ផ្សេងៗទៀតដូចជា៖ ឧបត្ថម្ភការប្រជុំគណៈបញ្ជាការឯកភាព, ឧបត្ថម្ភការប្រឆាំងគ្រឿងញៀន, និងឧបត្ថម្ភ[illegible]ភូមិ-ឃុំមានសុវត្ថិភាព [illegible] |

| ជំពូក | គណនី | អនុគណនី | បរិយាយ | សេចក្ដីពន្យល់ពីមាតិកាដីកា |
|---|---|---|---|---|
| 65 | | | ឧបត្ថម្ភធន | ចំណាយចរន្តការផ្ទេរសម្រាប់ឧបត្ថម្ភធនដល់រដ្ឋបាលដែនដីអង្គភាពសាធារណៈ គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល សហគ្រាស-សាធារណៈនិងអង្គភាពដែលមានលក្ខណៈសង្គមនិងវប្បធម៌ វិភាគទានរបស់រាជរដ្ឋាភិបាលដល់អង្គការអន្តរជាតិនានា ជំនួយនិងប្រាក់-វិភាជន៍សង្គម។ល។ |
| | 6501 | | ឧបត្ថម្ភធនរវាងរដ្ឋបាលសាធារណៈ | ចំណាយចរន្តការផ្ទេរសម្រាប់ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ចំណាយចរន្តការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀតនិងឧបត្ថម្ភធនដល់ក្រសួង-ស្ថាប័ន។ |
| | | 65011 | ឧបត្ថម្ភធនដល់រាជធានី-ខេត្ត | ចំណាយចរន្តសម្រាប់ឧបត្ថម្ភធនដល់រាជធានី-ខេត្ត។ |
| | | 65012 | ឧបត្ថម្ភធនដល់ក្រុង-ស្រុក-ខណ្ឌ | ចំណាយចរន្តសម្រាប់ឧបត្ថម្ភធនដល់ក្រុង-ស្រុក-ខណ្ឌ។ |
| | | 65013 | ឧបត្ថម្ភធនដល់ឃុំ-សង្កាត់ | ចំណាយចរន្តសម្រាប់ឧបត្ថម្ភធនដល់ឃុំ-សង្កាត់។ |
| | | 65014 | ឧបត្ថម្ភធនដល់ក្រសួង-ស្ថាប័ន | ចំណាយចរន្តសម្រាប់ឧបត្ថម្ភធនដល់ក្រសួង-ស្ថាប័ន។ |
| | | 65018 | ផ្សេងៗ | ឧបត្ថម្ភធនផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 6502 | | ឧបត្ថម្ភធនដល់អង្គការសាធារណៈ | ការឧបត្ថម្ភធនដល់អគ្គាធិការដ្ឋាន ដែលជាអាជ្ញាធរ អង្គភាពស្ថិតក្រោមអាណាព្យាបាលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងស្ថាប័នផ្សេងៗទៀត។ |
| | | 65021 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសេដ្ឋកិច្ច | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសេដ្ឋកិច្ច ដូចជា÷ ក្រុមប្រឹក្សាអភិវឌ្ឍវិស័យកសិកម្មនិងជនបទ, អាជ្ញាធរប្រេងកាតជាតិកម្ពុជា, អាជ្ញា-ធរអគ្គិសនីកម្ពុជា, គណៈកម្មការអភិរក្សនិងអភិវឌ្ឍតំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ, គណៈកម្មាធិការជាតិដើម្បីប្រជាជននិងអភិវឌ្ឍ, គណៈកម្មាធិការជាតិជម្រុញចលនាភូមិមួយផលិតផលមួយ, អាជ្ញាធរជាតិទេសចរណ៍កម្ពុជា។ល។ |
| | | 65022 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសង្គម | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសង្គម ដូចជា÷ គណៈកម្មាធិការជាតិសិទ្ធិមនុស្សកម្ពុជា, អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, គណៈ-កម្មាធិការជាតិអេស្កាប់, អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍, គណៈកម្មការស្រាវជ្រាវរុករកអដ្ឋិធាតុជនជាតិអាមេរិកនិងកងទ័ពវៀតណាមដែលបាត់ខ្លួននៅកម្ពុជា។ល។ |
| | | 65023 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈអប់រំ និងកីឡា | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈអប់រំ និងកីឡា មានដូចជា÷ ក្រុមប្រឹក្សាភាសាខ្មែរ, គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា, សមាគមជាតិកាយវប្បកម្ពុជា, ក្រុមប្រឹក្សាកីឡាកម្ពុជា។ល។ |
| | | 71002 | កម្រៃពីការងារគយ | ចំណូលទទួលបានពីការយកកម្រៃផ្សេងៗក្នុងការនាំចូល ដូចជា÷ ការនាំចូលទំនិញសម្រាប់លក់ក្នុងអគារលក់ទំនិញរួចពន្ធ, ការនាំចូលទំនិញឆ្លងកាត់, ការស្តុកទំនិញក្នុងឃ្លាំង ឬ ទីលានហួសកាលកំណត់, កម្រៃបំពេញបែបបទគយ, កម្រៃត្រួតពិនិត្យទំនិញតាមរយៈម៉ាស៊ីនស្កែន, និងកម្រៃផ្សេងៗទៀតដែលពុំមែនជាពន្ធ ឬ អាករ។ |
| | | 71003 | ពន្ធគយលើផលិតផលប្រេងកាត | ចំណូលទទួលបានពីការបង់ពន្ធលើការនាំចូលប្រេងឥន្ធនៈ។ |
| | | 71004 | អាករបន្ថែមលើផលិតផលប្រេងកាតសម្រាប់ថែទាំផ្លូវថ្នល់ | ចំណូលទទួលបានពីការបង់អាករបន្ថែមចំនួន ០,០២ ដុល្លារ ក្នុងមួយលីត្រ ចំពោះការនាំចូលប្រេងសាំង និង ០,០៤ ដុល្លារ ក្នុងមួយលីត្រ ចំពោះការនាំចូលប្រេងម៉ាស៊ូត ហើយចំណូលនេះប្រើប្រាស់សម្រាប់ថែទាំផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ។ |
| | | 71005 | ផលពីការលក់ទំនិញរឹបអូស និងទំនិញគ្មានការទាមទារ | ចំណូលទទួលបានពីការលក់ទំនិញផ្សេងៗ (ល្មើសច្បាប់ពន្ធដារ និងគយ) ដែលរឹបអូសបាន និងទំនិញគ្មានការទាមទារ។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | ចំណូលទទួលបានពីការបង់ពិន័យផ្សេងៗលើការនាំចូល។ |
| | | 71007 | ពន្ធនាំចូល (ជាបន្ទុករបស់រដ្ឋ) | ចំណូលប្រភេទនេះបានមកលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ និងទំនិញផ្សេងទៀត (ការកត់ត្រាជាចំណូលថវិកាក្នុងអនុគណនីនេះ គឺដើម្បីមានតុល្យភាពរវាងចំណាយថវិកាដែលជាបន្ទុករបស់រដ្ឋ)។ |
| | | 71008 | ពន្ធនិងអាករលើការនាំចូលផ្សេងៗ | ចំណូលពីការបង់ពន្ធ ឬអាករលើការនាំចូលផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | ចំណូលទទួលបានពីការបង់ពន្ធ អាករ និងកម្រៃផ្សេងៗ លើការនាំចេញ។ |
| | | 71011 | អាករលើការនាំចេញឈើ | ចំណូលទទួលបានពីការបង់អាករ លើការនាំចេញឈើគ្រប់ប្រភេទ។ |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | ចំណូលទទួលបានពីការបង់អាករលើការនាំចេញកៅស៊ូ។ |
| | | 71013 | អាករលើការនាំចេញផលិតផលគេលសិលា | ចំណូលទទួលបានពីការបង់អាករលើការនាំចេញផលិតផលគេលសិលា។ |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | ចំណូលទទួលបានពីការបង់អាករលើការនាំចេញទំនិញផ្សេងៗ ក្រៅពីឈើ, កៅស៊ូ, និងផលិតផលគេលសិលា។ |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | ចំណូលទទួលបានពីការពិន័យផ្សេងៗលើការនាំចេញដែលមិនគោរពតាមបទដ្ឋាន។ |
| | | 71018 | ពន្ធនិងអាករលើការនាំចេញផ្សេងៗ | ចំណូលពីការបង់ពន្ធ ឬ អាករលើការនាំចេញផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | | | **ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ** | ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋ ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា, ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម, ការឧបត្ថម្ភ អំណោយ, ផលហិរញ្ញវត្ថុ, ផលផ្សេងៗ, និងផលពិសេស។ |
| 72 | | | **ផលទុននៃទ្រព្យសម្បត្តិរដ្ឋ** | ចំណូលទទួលបានពីការជួល និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ។ |
| | 7200 | | ផលសម្បទាន | ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិរដ្ឋ ដូចជា÷ ការជួលឡូត៍នេសាទ, ការជួលដីព្រៃឈើ, ការជួលផែនទីកសម្រាប់ធ្វើអាជីវកម្មប្រេងកាត, ការជួលដីសម្រាប់រុករករ៉ែ, និងការជួលដីធ្លីផ្សេងៗទៀត។ |
| | | 72001 | ផលពីនេសាទ | ចំណូលទទួលបានពីការជួលឡូត៍នេសាទ។ |
| | | 72002 | ផលពីព្រៃឈើ | ចំណូលទទួលបានពីផលព្រៃឈើ ដូចជា÷ ចំណូលពីការលក់ឈើឈរ, អនុផលព្រៃឈើ, និងចំណូលពីបទល្មើសព្រៃឈើ ការលក់ឈើ [illegible] ដែលរឹបអូសបាន។ |
| | | 72003 | សម្បទានប្រេងកាត | ចំណូលទទួលបានពីការជួលដី ឬ ផែនទីកដែលមានប្រេងកាតទៅឱ្យឯកជនដើម្បីធ្វើការរុករក, ស្រាវជ្រាវ, ឬ ធ្វើអាជីវកម្មប្រេង [illegible] បានពីសួយសារ និងភាគចំណែករបស់រដ្ឋពីការធ្វើអាជីវកម្ម។ |
| | | 72004 | សម្បទានរ៉ែ | ចំណូលទទួលបានពីបុព្វលាភ, ឈ្នួលផ្ទៃក្រឡាសម្រាប់ដំណាក់កាលសិក្សាស្រាវជ្រាវរុករករ៉ែ, ដំណាក់កាលធ្វើអាជីវកម្មរ៉ែ, ចំណូលទទួលបានពីសួយសាររ៉ែ, និងភាគចំណែករបស់រដ្ឋពីការធ្វើអាជីវកម្ម ដូចជា÷ មាស, ខ្សាច់, គ្រួស, បុកស៊ីត, ដែក, ឧស្ម័នធម្មជាតិ, ត្បូងថ្ម, ត្បូង, មាស...។ល។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 72005 | សម្បទានដីសេដ្ឋកិច្ច | ចំណូលទទួលបានពីកិច្ចសន្យា ឬ កិច្ចព្រមព្រៀងសម្បទានដីសេដ្ឋកិច្ច។ |
| | | 72006 | ចំណតយានជំនិះ | ចំណូលទទួលបានដោយផ្តល់សិទ្ធិធ្វើអាជីវកម្មចំណតយានជំនិះគ្រប់ប្រភេទដូចជា៖ រថយន្ត, ម៉ូតូ, កង់, ដល់ភាគីឯកជន។ |
| | | 72007 | ចំណតជលយាន | ចំណូលទទួលបាន ដោយផ្តល់សិទ្ធិធ្វើអាជីវកម្មទូក, កាណូត, កប៉ាល់, ការប្រើប្រាស់កំពង់ផែ, ចំណតជើងទឹក ដល់ភាគីឯកជន។ |
| | | 72008 | ផលសម្បទានផ្សេងៗ | ចំណូលពីការជួលកោះ និងពីការផ្តល់សម្បទានផ្សេងៗ។ |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | កត់ត្រាចំណូលទទួលបានពីសហគ្រាសសាធារណៈ ដូចជា៖ ចំនួនលើសនៃទុនចល័ត, ប្រាក់ចំណេញ, ការបង់ប្រាក់រំលស់, និងទុនផ្សេងៗទៀត។ |
| | | 72011 | ការបង់ចំនួនលើសនៃទុនចល័ត | ចំណូលទទួលបានពីការបង់មកវិញនូវទុនចល័តដែលលើសពីតម្រូវការរបស់សហគ្រាសសាធារណៈ។ |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | ចំណូលទទួលបានពីការបង់ភាគលាភរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនដែលចម្រុះរដ្ឋមានភាគហ៊ុន ក្រោយការិយបរិច្ឆេទបិទបញ្ជីប្រចាំឆ្នាំ ដូចជា៖ ប្រាក់ចំណេញរបស់កំពង់ផែស្វយ័ត, កាំសាប, អគ្គិសនីកម្ពុជា, រដ្ឋាករទឹក...។ល។ |
| | | 72014 | ប្រាក់ធានារ៉ាប់រងសង្គម | ចំណូលប្រភេទនេះបានមកពីការបង់របស់សហគ្រាសសាធារណៈសម្រាប់ផលប៉ះពាល់ទៅលើសុខភាពបុគ្គលិក, កម្មករ...។ល។ |
| | | 72018 | ផលទុនផ្សេងៗពីសហគ្រាសសាធារណៈ | ផលទុនផ្សេងៗទៀតរបស់សហគ្រាសសាធារណៈក្រៅពីអនុគណនីខាងលើ ។ |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | កត់ត្រាចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិដូចជាក្រៅពីដីធ្លី និងអគារ ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិ និងចំណូលទទួលបានពីការផ្តល់សេវាដោយរដ្ឋ។ |
| | 7300 | | ផលទុនតាមវិស័យ | ចំណូលទទួលបានពីការធ្វើអាជីវកម្ម, ការផ្តល់សេវាកម្ម, និងការផ្តល់សិទ្ធិ ពីវិស័យពាក់ព័ន្ធ របស់ក្រសួង-ស្ថាប័ន និងអង្គភាពរដ្ឋ។ |
| | | 73001 | ផលទុនអាកាសចរស៊ីវិល | ចំណូលពីការបង់សួយសារលើជើងហោះហើរមកប្រទេសកម្ពុជា, កម្រៃសេវានាំផ្លូវចុះចត ហោះឡើងនៅអាកាសយានដ្ឋាន និងសេវានាំផ្លូវហោះឆ្លងកាត់ដែនអាកាសកម្ពុជា ដែលទទួលបានពីក្រុមហ៊ុនអាកាសចរណ៍នានា ព្រមទាំងចំណូលបែងចែកពីបណ្តាក្រុមហ៊ុនឯកជន ដែលបានចុះកិច្ចព្រមព្រៀងឱ្យធ្វើសេវាកម្ម, អាជីវកម្ម, និងវិនិយោគ លើវិស័យអាកាសចរណ៍។ |
| | | 73002 | ផលទុននៃសកម្មភាពភាពយន្ត | ចំណូលទទួលបានពីការអនុញ្ញាតឱ្យថតខ្សែភាពយន្ត។ |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | ចំណូលទទួលបានពីការលក់សំបុត្រចូលទស្សនា។ ចំណូលទទួលបានពីការចូលទស្សនារមណីយដ្ឋានធម្មជាតិ, ការជួលស្តង់[illegible] ជួលកន្លែងលក់, ជួលសំលៀកបំពាក់សម្រាប់ភ្ញៀវទេសចរណ៍...។ល។ |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | ចំណូលទទួលបានពីការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិ ព្រះបរមរាជវាំង ការអនុញ្ញាតឱ្យថតចម្លងបទចម្រៀង។ |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | ចំណូលពីការផ្តល់សេវាផ្ញើរបញ្ញើសំបុត្រ ឬ ឥវ៉ាន់, ចំណូលពីសហគ្រាសទូរគមនាគមន៍កម្ពុជា, ចំណូលពីការបែងចែកពីក្រុមហ៊ុនទូរស័ព្ទចល័ត និងចំណូលពីការប្រើប្រាស់សេវាទូរគមនាគមន៍។ |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | ចំណូលពីកម្រៃសេវាសោតទស្សន៍, ពីស្ថានីយវិទ្យុ, និងទូរទស្សន៍, កម្រៃពីការផ្សព្វផ្សាយពាណិជ្ជកម្មតាមវិទ្យុ និងទូរទស្សន៍។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 73007 | ផលចូលនៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | ចំណូលទទួលបានពីចំណែកគិតជាភាគរយនៃផលចំណេញលើសកម្មភាពផលិតទឹកស្អាត និងអគ្គិសនី បង់ដោយរដ្ឋាករទឹកនិងផលពីសេវាផ្គត់ផ្គង់ទឹកផ្សេងទៀត និងពីអ្នកផ្គត់ផ្គង់អគ្គិសនី។ |
| | | 73008 | ផលចូលផ្សេងៗទៀត | ចំណូលទទួលបានពីផលចូលផ្សេងៗទៀតរបស់ស្ថាប័នរដ្ឋ និងសហគ្រាសសាធារណៈ ក្រៅពីអនុគណនីខាងលើ ដូចជាចំណូល ២% លើចំណែកនៃផលិតផលស្រាបៀ ចំណូលពីពាណិជ្ជសញ្ញា ចំណូលពីសេវាសោធនសម្ព័ន្ធ។ ចំណូលទទួលបានពីភាគទានលូទឹកស្អុយ ១០% លើថ្លៃប្រើប្រាស់ទឹកស្អាត បង់ដោយរដ្ឋាករទឹកស្វយ័ត។ |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | ចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ។ |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខ្ទចខាត សម្ភារសិក្សា | ចំណូលទទួលបានពីការលក់សម្ភារបរិក្ខារចាស់ៗ ដូចជា៖ តុ, ទូ, កៅអី...។ល។ ដែលមិនបានកត់ត្រាជាអចលនវត្ថុ។ |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | ចំណូលទទួលបានពីការលក់សៀវភៅការងារ សន្លឹកតែមប្រើ ឯកសារផ្សេងៗ និងលតាប័ត្ររបស់ពន្ធដារនិងគយ ចំណូលពីការចេញលិខិតបញ្ជាក់ពាក់ព័ន្ធបទល្មើសផ្សេងៗ ចំណូលពីការលក់ឯកសារដេញថ្លៃ...។ល។ |
| | | 73013 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ | ចំណូលទទួលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី ដូចជា៖ ដែក, ទុយោ, ច្រូងមាត់, ទា, កំទេចកំទីថ្ម, និងសត្វពាហនៈ...។ល។ |
| | | 73014 | ការលក់ផលិតផលកសិកម្ម | ចំណូលពីការលក់ផលិតផលកសិកម្ម ដូចជា៖ ស្រូវពូជ, ពោត, សណ្តែក, ពូជសត្វ, កូនរុក្ខជាតិ...។ល។ |
| | | 73015 | ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬ ខូច | ចំណូលទទួលបានពីការលក់តោចក្រយានយន្ត, យានយន្ត, រថយន្ត, ជលយាន, គ្រឿងចក្រ។ល។ ចាស់ៗ ឬ ខូច ដែលមិនបានកត់ត្រាជាអចលនវត្ថុ។ |
| | | 73016 | ការលក់ឧបករណ៍អេឡិចត្រូនិចចាស់ៗ ឬ ខូច | ចំណូលទទួលបានពីការលក់សម្ភារបរិក្ខារចាស់ៗ ដូចជា៖ កុំព្យូទ័រ, ព្រីនធើ, អិលស៊ីឌីប្រូជិចទ័រ, យូភីអេស...។ល។ ដែលមិនបានកត់ត្រាជាអចលនវត្ថុ។ |
| | | 73017 | ការលក់ឧបករណ៍អគ្គិសនីចាស់ៗ ឬ ខូច | ចំណូលទទួលបានពីការលក់ម៉ាស៊ីនភ្លើង, បង្គោលភ្លើង, ឧបករណ៍ទប់ភ្លើង...។ល។ ចាស់ៗ ឬ ខូច ដែលមិនបានកត់ត្រាជាអចលនវត្ថុ។ |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (1) | ចំណូលទទួលបានពីការចុះបញ្ជីគណបក្សនយោបាយ, ការបង្កើតសហគ្រាស, ការបង់សិទ្ធិប្រឡង, សោហ៊ុយយុត្តិធម៌, និងចំណូលពីសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំណត់ដោយច្បាប់។ |
| | | 73022 | ផលពីការចុះបញ្ជីគណបក្សនយោបាយ | ផលពីការចុះបញ្ជីគណបក្សនយោបាយ។ |
| | | 73023 | ផលពីការបង្កើតសហគ្រាស | ចំណូលទទួលបានពីការចុះបញ្ជីធ្វើពាណិជ្ជកម្ម, ស្លាកសញ្ញា, ចុះបញ្ជីពន្ធដារ, ការធ្វើបច្ចុប្បន្នភាពសហគ្រាស, ចុះបញ្ជីឈ្មោះអ្នកទទួលការសាងសង់លទ្ធកម្ម, ច្បាប់អាជីវកម្មយានយន្ត...។ល។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | ចំណូលទទួលបានពីភាគទានដែលបង់ដោយសិស្សដើម្បីទទួលបានសិទ្ធិប្រឡង។ |
| | | 73026 | ចំណូលពីប្រដាប់ក្ដី | ចំណូលទទួលបានពីការជំនុំជម្រះក្ដី (ពន្ធហ្មឺង, ពន្ធសមមាត្រ, ពន្ធបណ្ដឹងសាទុក្ខ, ពន្ធឧទ្ធរណ៍, ពន្ធសកម្មភាពតុលាការ, ពាក្យសុំរបបត្តសាលដីកា និងពាក្យសុំអន្តរាគមន៍...)។ |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | ចំណូលទទួលបានពីការបញ្ជាក់លើហត្ថលេខាលិខិតចម្លងច្បាប់ដើម, វិញ្ញាបនប័ត្រ, លិខិតបញ្ជាក់ការសិក្សា, ព្រឹត្តិបត្រពិន្ទុ, លិខិតផ្សេងៗ, និង ចំណូលពីការអនុញ្ញាតផ្សេងៗ ដល់អ្នកប្រើប្រាស់ដែលបានធានាអះអាងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងចំណូលពីការគ្រប់គ្រងរដ្ឋបាលផ្សេងៗ។ |
| | 7304 | | ការផ្ដល់សេវាកម្ម | ចំណូលទទួលបានពីការផ្ដល់សេវាដោយរដ្ឋ។ |
| | | 73041 | ផលនៃការដឹកជញ្ជូនទំនិញ | ចំណូលទទួលបានពីការផ្ដល់សេវាដឹកជញ្ជូនទំនិញដោយរដ្ឋ។ |
| | | 73042 | កម្រៃនៃការថែទាំ | ចំណូលទទួលបានពីការផ្ដល់សេវាថែទាំ ដូចជាចំណូលមួយចំណែកបានពីការពិនិត្យ និងព្យាបាលអ្នកជំងឺ ដោយមន្ទីរពេទ្យរដ្ឋ។ |
| | | 73043 | សេវាសុរិយោដី | ចំណូលទទួលបានពីការចុះបញ្ជីក្បាលដី និងការចេញប្លង់កាន់កាប់ដីធ្លី ផ្ទះសម្បែង។ |
| | | 73044 | សេវាសំណង់ | ចំណូលទទួលបានពីការអនុញ្ញាតឱ្យសាងសង់។ |
| | | 73045 | សេវាផ្ដល់ព្រឹត្តិបត្រថ្កោលទោស | ចំណូលបានពីការផ្ដល់ព្រឹត្តិបត្រថ្កោលទោសជូនប្រជាពលរដ្ឋ, សិស្ស, និស្សិត, កម្មករ...ដែលបញ្ជាក់ថាមានទោស ឬ គ្មានទោស។ |
| | | 73046 | សេវាអប់រំ | ចំណូលពីកម្រៃនិស្សិតថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតថ្នាក់ត្រៀម...។ |
| | | 73047 | សេវាលើពន្ធប្រថាប់ត្រា | ចំណូលទទួលបានពីសេវាលើពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ។ |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | ចំណូលទទួលបានពីផលនៃសេវាផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 7305 | | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងទៀត | ចំណូលទទួលបានពីទ្រព្យសម្បត្តិអចល័ត កម្រៃសេវា និងចំណូលផ្សេងៗ របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលកំណត់ដោយច្បាប់។ |
| | | 73051 | ចំណូលពីសត្តឃាតដ្ឋាន | ចំណូលទទួលបានពីកន្លែងធ្វើអាជីវកម្មពិឃាតសត្វនៅតាមសត្តឃាតដ្ឋាន។ |
| | | 73052 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | ចំណូលទទួលបានពីការជួលតូប, តន, ស្តង់លក់ដូរក្នុងទីផ្សារ។ |
| | | 73053 | ចំណូលពីកំពង់ចម្លង | ចំណូលទទួលបានពីការបម្រើសេវាកម្មចម្លងអ្នកធ្វើដំណើរនៅតាមកំពង់ផែ, ផងទឹក, ផងបណ្ដោយ ដែលរដ្ឋបានកំណត់។ |
| | | 73054 | ចំណូលពីយៀត្រី និងកន្លែងបែងចែកផលិតផល | ចំណូលទទួលបានពីអាជីវកម្មដែលធ្វើការប្រមូលត្រី និងបែងចែកការប្រើប្រាស់ផលនេសាទ ដែលរដ្ឋបានកំណត់។ |
| | | 73055 | ចំណូលពីកាស៊ីផ្សារ | ចំណូលដែលបានប្រមូលពីអាជីវករលក់ដូរក្នុងនិងក្រៅទីផ្សារដែលរដ្ឋបានកំណត់។ |
| | | 73058 | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងៗ | ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិអចល័តផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | ចំណូលទទួលបានពីកាតព្វកិច្ចកាស៊ីណូ, ឆ្នោត, ល្បែងភ្នាល់ផ្សេងៗ, ពីអាកាសយានដ្ឋាន, អាជ្ញាប័ណ្ណនាំចេញ, អាជ្ញាប័ណ្ណក្នុងស្រុក, កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ។ |
| | | 73061 | ចំណូលពីកាតព្វកិច្ចកាស៊ីណូ | ចំណូលបានមកពីកាតព្វកិច្ចកាស៊ីណូ ចំណូលពីស្លតម៉ាស៊ីន។ |
| | | 73062 | ចំណូលពីកាតព្វកិច្ចឆ្នោត | ចំណូលកាតព្វកិច្ចពីឆ្នោត។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្ដីពន្យល់ពីមាតិកាចំណាត់ថ្នាក់ |
|---|---|---|---|---|
| | | 73063 | ចំណូលកាតព្វកិច្ចពីល្បែងភ្នាល់ផ្សេងៗ | ចំណូលកាតព្វកិច្ចពីល្បែងភ្នាល់ផ្សេងៗ ដូចជាការភ្នាល់បាល់...។ល។ |
| | | 73065 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | ចំណូលបានមកពីការផ្ដល់អាជ្ញាប័ណ្ណនាំចេញគ្រប់បែបយ៉ាង។ |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | ចំណូលបានមកពីការផ្ដល់អាជ្ញាប័ណ្ណធ្វើអាជីវកម្មក្នុងស្រុក ដូចជា៖ អាជ្ញាប័ណ្ណធ្វើអាជីវកម្មរ៉ែ, អាជ្ញាប័ណ្ណកាស៊ីណូ, អាជ្ញាប័ណ្ណឆ្នោត, អាជ្ញាប័ណ្ណអចលនទ្រព្យ, អាជ្ញាប័ណ្ណធានារ៉ាប់រងអាជ្ញាប័ណ្ណទេសចរណ៍...។ |
| | | 73067 | តម្លៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ចំណូលទទួលបានពីការផ្ដល់កូតា និងអាជ្ញាប័ណ្ណនាំចេញសំលៀកបំពាក់ ស្បែកជើង...។ល។ |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | ចំណូលទទួលបានពីការជួលទ្រព្យសម្បត្តិរដ្ឋ ដូចជា៖ ការជួលដីនិងអគារ, ការជួលអគារ ឬ សំណង់ផ្សេងៗ, ការជួលសម្ភារបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ...។ល។ |
| | | 73071 | ការជួលដីទំនេរ | ចំណូលទទួលបានពីការជួលដីរបស់រដ្ឋ។ |
| | | 73072 | ការជួលដីមានអគារ | ចំណូលទទួលបានពីការជួលដី និងអគារទាំងមូលរបស់រដ្ឋ។ |
| | | 73073 | ការជួលអគារ ឬ សំណង់ផ្សេងៗ | ចំណូលទទួលបានពីការជួលផ្នែកនៃអគារ ឬ សំណង់ផ្សេងៗ ដូចជា៖ ការជួលការិយាល័យការជួលអាហារដ្ឋាន កន្លែងថតចម្លង កន្លែងផ្សព្វផ្សាយផលិតផលផ្សេងៗ កន្លែងលក់ដូរ...។ល។ |
| | | 73074 | ការជួលសម្ភារបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ | ចំណូលទទួលបានពីការជួលសម្ភារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្ររបស់រដ្ឋ។ |
| | | 73078 | ផលពីការជួលផ្សេងៗ | ចំណូលទទួលបានពីការជួលផ្សេងៗដែលមិនមានក្នុងអនុគណនីខាងលើ ដូចជា៖ ភាគចំណែករបស់រដ្ឋពីការបែងចែកចំណូលដុល (GOR) តាមកិច្ចព្រមព្រៀង ឬ កិច្ចសន្យាផ្សេងៗ...។ល។ |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (2) | ចំណូលទទួលបានពីការផ្ដល់លិខិតឆ្លងដែន, ទិដ្ឋាការ, ការចុះបញ្ជីយានយន្ត, ការផ្ដល់ប័ណ្ណបើកបរ, និងផលពីការត្រួតពិនិត្យអនាម័យសត្វ ការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន។ |
| | | 73081 | ចំណូលពីការផ្ដល់លិខិតឆ្លងដែន | ចំណូលពីសេវាផ្ដល់លិខិតឆ្លងដែន និងផ្ដល់ប័ណ្ណឆ្លងដែន។ |
| | | 73082 | ចំណូលពីការផ្ដល់ទិដ្ឋាការ | ចំណូលពីតម្លៃសេវាផ្ដល់ទិដ្ឋាការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ទៅតាមប្រភេទទិដ្ឋាការដែលបានកំណត់ឱ្យបង់ថ្លៃ ដូចជា៖ ចំណូលពីការផ្ដល់ទិដ្ឋាការស្នាក់នៅជាដើម។ |
| | | 73083 | ចំណូលពីការលក់លេខចុះបញ្ជីយានយន្ត | ចំណូលពីការលក់លេខចុះបញ្ជីយានយន្តគ្រួសារ និងរថយន្តដឹកទំនិញស្រាល មានជាអាទិ៍៖ ការលក់លេខពិសេស លក់លេខធម្មតា និងលេខផ្ដោះសើរ។ |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | ចំណូលពីការផ្ដល់ស្លាកលេខ និងផ្ដល់ប័ណ្ណសម្គាល់យានយន្ត និងជលយានគ្រប់ប្រភេទ។ ផ្ដល់ប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងប័ណ្ណសម្គាល់ការបង់ពន្ធលើអចលនទ្រព្យ។ |
| | | 73085 | ចំណូលពីការផ្ដល់ប័ណ្ណបើកបរគ្រប់ប្រភេទ | ចំណូលពីតម្លៃប័ណ្ណបើកបរយានយន្ត និងជលយានគ្រប់ប្រភេទ។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | ចំណូលទទួលបានពីការផ្តល់សេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលមានដើមកំណើតពីសត្វ, ការធ្វើចរាចរសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងការសម្លាប់សត្វ និងការសម្លាប់សត្វនៅសត្តឃាតដ្ឋាន...។ល។ |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | ចំណូលទទួលបានពីការត្រួតពិនិត្យគុណភាព, គុណភាពឱសថ, កាសែត និងភាពយន្ត, និងការគោរពបទដ្ឋាន និងចំណូលពីការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការឃ្លាំមើលការអនុវត្តគម្រោង, ចំណូលពីការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និងជលយាន...។ល។ |
| 74 | | | ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | កត់ត្រាចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្មដែលត្រូវបង់ទៅឱ្យរដ្ឋ ចំពោះបទល្មើសនឹងច្បាប់ ឬ បទបញ្ញារដ្ឋបាល។ ការពិន័យនិងការដាក់ទណ្ឌកម្មសារពើពន្ធ ដែលទាក់ទងនឹងពន្ធពិសេសមួយ ត្រូវបានចុះជាចំណូលក្នុងផ្នែកនេះ ប៉ុន្តែការផាកពិន័យនិងការដាក់ទណ្ឌកម្មសារពើពន្ធផ្សេងៗទៀត ត្រូវបានកត់ត្រានៅក្នុងចំណូលសារពើពន្ធផ្សេងៗទៀត។ រួមទាំងការពិន័យឯទៀតដែលជាចំណូលមិនមែនសារពើពន្ធ។ |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | ចំណូលទទួលបានពីការពិន័យអន្តរការណ៍ជាប្រាក់ចំពោះការមិនអនុវត្តតាមកិច្ចសន្យានៃការជួលអគារ ឬ ដីធ្លី... និងបទល្មើសច្បាប់ចរាចរណ៍។ |
| | | 74011 | ការពិន័យជាប្រាក់លើបទល្មើសចរាចរណ៍ផ្លូវគោក | ចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ ឬ ការផ្តន្ទាទោសពិន័យជាប្រាក់ ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក មានជាអាទិ៍៖ ការមិនគោរពស្លាកសញ្ញា និងភ្លើងសញ្ញាចរាចរណ៍, មិនពាក់មួកសុវត្ថិភាព, ជិះហួសល្បឿនកំណត់...។ល។ |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | ចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ ឬ ការផ្តន្ទាទោសពិន័យជាប្រាក់ ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិនានា ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត ដែលនៅមានជាធរមាន។ មានជាអាទិ៍៖ ការពិន័យជាប្រាក់ចំពោះការមិនអនុវត្តតាមលក្ខខណ្ឌកិច្ចសន្យានៃការជួលអគារ ឬ ដីធ្លី, រថយន្តដឹកទំនិញលើសទម្ងន់កម្រិតកំណត់អតិបរមា...។ល។ |
| | 7403 | | ចំណូលពីការរឹបអូស | ចំណូលទទួលបានពីការរឹបអូសប្រាក់កក់ និងទ្រព្យសម្បត្តិ ចំពោះការមិនអនុវត្តតាមលក្ខខណ្ឌកិច្ចសន្យា។ |
| | | 74031 | ចំណូលពីការរឹបអូសប្រាក់កក់ | ចំណូលទទួលបានពីការរឹបអូសប្រាក់កក់នៃការដេញថ្លៃ និងប្រាក់កក់នៃការអនុវត្តកិច្ចសន្យា។ |
| | | 74032 | ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ | ចំណូលពីការលក់ទ្រព្យសម្បត្តិរឹបអូសពីការបង្ក្រាបបទល្មើសគ្រឿងញៀន។ |
| | 7408 | | ផលពីការពិន័យផ្សេងៗ | ចំណូលពីការចាត់វិធានការពិន័យផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | | 74081 | ផលពីការពិន័យផ្សេងៗ | ចំណូលពីការចាត់វិធានការពិន័យផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| 75 | | | ការឧបត្ថម្ភ និង អំណោយ | ការឧបត្ថម្ភឬអំណោយ អាចជាហិរញ្ញវត្ថុ ឬ សម្ភារ។ ពាក្យ ការឧបត្ថម្ភ ត្រូវបានប្រើប្រាស់សម្រាប់ការបង្វែរធ្វើដោយរដ្ឋ ឬ អង្គការអន្តរជាតិ រីឯអំណោយមានធម្មជាតិដូចគ្នានឹងការឧបត្ថម្ភ ប៉ុន្តែបានមកពីបុគ្គលឯកជន (បុគ្គល ឬ សមាគម)។ |
| | 7501 | | ឧបត្ថម្ភធនពីថ្នាក់ជាតិ | ចំណូលឧបត្ថម្ភពីថវិកាជាតិ។ |
| | | 75011 | ឧបត្ថម្ភធនពីក្រសួង-ស្ថាប័ន | ចំណូលឧបត្ថម្ភពីក្រសួង-ស្ថាប័ន។ |
| | | 75012 | ឧបត្ថម្ភធនពីមន្ទីរជំនាញ | ចំណូលឧបត្ថម្ភពីមន្ទីរជំនាញ។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 75013 | ឧបត្ថម្ភធនពីសហគ្រាសសាធារណៈ | ចំណូលឧបត្ថម្ភពីសហគ្រាសសាធារណៈ។ |
| | | 75014 | ឧបត្ថម្ភធនពីគ្រឹះស្ថានសាធារណៈរដ្ឋបាល | ចំណូលឧបត្ថម្ភពីគ្រឹះស្ថានសាធារណៈរដ្ឋបាល។ |
| | 7502 | | ឧបត្ថម្ភធនរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ | ចំណូលឧបត្ថម្ភថវិកា រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 75021 | ឧបត្ថម្ភធនពីរាជធានី-ខេត្ត | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលរាជធានី-ខេត្ត។ |
| | | 75022 | ឧបត្ថម្ភធនពីក្រុង-ស្រុក-ខណ្ឌ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលក្រុង-ស្រុក-ខណ្ឌ។ |
| | | 75023 | ឧបត្ថម្ភធនពីឃុំ-សង្កាត់ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលឃុំ-សង្កាត់។ |
| | 7503 | | ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន | ចំណូលទទួលបានពីការចែករំលែកពីសមាសភាគអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | | 75031 | ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន | ចំណូលទទួលបានពីការចែករំលែកពីសមាសភាគអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| | 7504 | | ឧបត្ថម្ភធនពីក្រៅប្រទេស | ចំណូលទទួលបានពីឧបត្ថម្ភធនពីក្រៅប្រទេស។ |
| | | 75041 | ឧបត្ថម្ភធនពីក្រៅប្រទេសទ្វេភាគី | ចំណូលទទួលបានពីឧបត្ថម្ភធនពីក្រៅប្រទេសទ្វេភាគី។ |
| | | 75042 | ឧបត្ថម្ភធនពីក្រៅប្រទេសពហុភាគី | ចំណូលទទួលបានពីឧបត្ថម្ភធនពីក្រៅប្រទេសពហុភាគី។ |
| | 7506 | | ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ | ចំណូលទទួលបានពីការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជាក្រសួង-ស្ថាប័ន មន្ទីរជំនាញ រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ។ |
| | | 75061 | ពីក្រសួង-ស្ថាប័ន | ចំណូលទទួលបានពីការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជាក្រសួង-ស្ថាប័ន។ |
| | | 75062 | ពីមន្ទីរជំនាញ | ចំណូលទទួលបានពីការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជាមន្ទីរជំនាញ។ |
| | | 75063 | ពីរាជធានី-ខេត្ត | ចំណូលទទួលបានពីការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជារាជធានី-ខេត្ត។ |
| | | 75064 | ពីក្រុង-ស្រុក-ខណ្ឌ | ចំណូលទទួលបានពីការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមជាក្រុង-ស្រុក-ខណ្ឌ។ |
| | | 75068 | ផ្សេងៗ | ចំណូលទទួលបានពីការអនុវត្តមុខងារជាភ្នាក់ងារផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 7507 | | ចំណូលបរិភាគក្នុងនិងក្រៅប្រទេស | ចំណូលទទួលបានពីប្រជាពលរដ្ឋ-សប្បុរសជនក្នុងនិងក្រៅប្រទេស។ |
| | | 75071 | ចំណូលបរិភាគពីប្រជាពលរដ្ឋ-សប្បុរសជន ក្នុងនិងក្រៅប្រទេស | ចំណូលទទួលបានពីប្រជាពលរដ្ឋ-សប្បុរសជនក្នុងនិងក្រៅប្រទេស។ |
| | 7508 | | ចំណូលពីប្រភពផ្សេងៗ | ចំណូលទទួលបានពីប្រភពផ្សេងៗ ដូចជាចំណូលទទួលបានពីការរួមចំណែករបស់រោងចក្រ សហគ្រាស អាជីវកម្ម សម្រាប់ទ្រទ្រង់ ឬ ថែរក្សាបរិស្ថាន។ |
| | | 75081 | ផលពីការរួមចំណែកការពារបរិស្ថាន | ចំណូលទទួលបានពីការរួមចំណែករបស់រោងចក្រ សហគ្រាស អាជីវកម្ម សម្រាប់ទ្រទ្រង់ ឬ ថែរក្សាបរិស្ថាន (ទាយជ្ជទានបរិស្ថាន)។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 75082 | ផលពីការរួមចំណែកការពារព្រៃឈើ | ចំណូលបានមកពីឥណទានកាបោន (Cabon Credit) តាមរយៈការចុះកិច្ចសន្យារវាងរដ្ឋាភិបាលជាមួយនឹងក្រុមហ៊ុន ឬ ភាគីឯកជន ដើម្បីលើកទឹកចិត្តចំពោះការការពារនិងការថែរក្សាព្រៃឈើនៅតំបន់អភិរក្សព្រៃឈើ។ |
| | | 75083 | ឧបត្ថម្ភជាសម្ភារបរិក្ខារ ទ្វេភាគី | ការទទួលបាននូវឧបត្ថម្ភជាសម្ភារបរិក្ខារ ដូចជា ឱសថ...។ល។ ដែលមិនមែនជាហិរញ្ញវត្ថុ ពីទ្វេភាគី។ |
| | | 75084 | ឧបត្ថម្ភជាសម្ភារបរិក្ខារ ពហុភាគី | ការទទួលបាននូវឧបត្ថម្ភជាសម្ភារបរិក្ខារ ដូចជា ឱសថ...។ល។ ដែលមិនមែនជាហិរញ្ញវត្ថុ ពីពហុភាគី។ |
| | | 75085 | ឧបត្ថម្ភជាសម្ភារបរិក្ខារ ពីក្រសួងអាណាព្យាបាល | ការទទួលបាននូវឧបត្ថម្ភជាសម្ភារបរិក្ខារ ដូចជា ឱសថ...។ល។ ដែលមិនមែនជាហិរញ្ញវត្ថុ ពីក្រសួងអាណាព្យាបាល។ |
| | | 75088 | ចំណូលពីប្រភពផ្សេងៗទៀត | ចំណូលទទួលបានពីប្រភពផ្សេងៗទៀត។ |
| | 7510 | | មូលនិធិបំរុង | មូលនិធិបានមកពីការប្រមូលយោងអតិរេកថវិកាពីឆ្នាំមុនៗសម្រាប់ចំណាយវិនិយោគ។ |
| | | 75101 | អតិរេកនៃការិយបរិច្ឆេទ | គណនីនេះតាងឱ្យអតិរេកថវិកាដែលបានយោងមកនិងជាហិរញ្ញប្បទានសម្រាប់ចំណាយនៅការិយបរិច្ឆេទបន្ទាប់។ គណនីនេះត្រូវបានបង្ហាញតែនៅលើគម្រោងថវិកាតែប៉ុណ្ណោះ ហើយពុំមានកិច្ចបញ្ជិកាគណនេយ្យជាចំណូលថវិកាទេ។ ក្នុងករណីដែលអតិរេកមិនត្រូវបានប្រើប្រាស់ ក្នុងគម្រោងថវិកាប្រចាំឆ្នាំពុំមានការបង្ហាញតួលេខនៃគណនីនេះ តែតួលេខអតិរេកមាននៅក្នុងគណនីយោងជាថ្មី ក្នុងបញ្ជីគណនេយ្យ។ |
| | 7511 | | ឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីថវិកាជាតិសម្រាប់ចំណាយវិនិយោគ។ |
| | | 75111 | ឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីក្រសួង-ស្ថាប័នសម្រាប់ចំណាយវិនិយោគ។ |
| | | 75112 | ឧបត្ថម្ភធនពីមន្ទីរជំនាញសម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីមន្ទីរជំនាញសម្រាប់ចំណាយវិនិយោគ។ |
| | | 75113 | ឧបត្ថម្ភធនពីសហគ្រាសសាធារណៈសម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីសហគ្រាសសាធារណៈសម្រាប់ចំណាយវិនិយោគ។ |
| | | 75114 | ឧបត្ថម្ភធនពីគ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីគ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ចំណាយវិនិយោគ។ |
| | 7512 | | ឧបត្ថម្ភធនរវាងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភរវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយវិនិយោគ។ |
| | | 75121 | ឧបត្ថម្ភធនពីរាជធានី-ខេត្ត សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលរាជធានី-ខេត្ត សម្រាប់ចំណាយវិនិយោគ។ |
| | | 75122 | ឧបត្ថម្ភធនពីក្រុង-ស្រុក-ខណ្ឌ សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលក្រុង-ស្រុក-ខណ្ឌ សម្រាប់ចំណាយវិនិយោគ។ |
| | | 75123 | ឧបត្ថម្ភធនពីឃុំ-សង្កាត់ សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភពីថវិការដ្ឋបាលឃុំ-សង្កាត់ សម្រាប់ចំណាយវិនិយោគ។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | 7513 | | ចំណូលពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន | ចំណូលពីការរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋានទៅក្នុងតម្លៃគម្រោងអភិវឌ្ឍ។ |
| | | 75131 | ចំណូលពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ | ចំណូលពីការរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋានទៅក្នុងតម្លៃគម្រោងអភិវឌ្ឍ។ |
| | 7514 | | ឧបត្ថម្ភធនពីក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភធនមូលធនពីក្រៅប្រទេសសម្រាប់ចំណាយវិនិយោគ។ |
| | | 75141 | ឧបត្ថម្ភធនពីក្រៅប្រទេស-ទ្វេភាគី សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភធនមូលធនពីក្រៅប្រទេស-ទ្វេភាគី សម្រាប់ចំណាយវិនិយោគ។ |
| | | 75142 | ឧបត្ថម្ភធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយវិនិយោគ | ចំណូលឧបត្ថម្ភធនមូលធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយវិនិយោគ។ |
| | 7517 | | ចំណូលពីប្រជាពលរដ្ឋ-សប្បុរសជនក្នុងនិងក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | ចំណូលដែលបានពីប្រជាពលរដ្ឋ សប្បុរសជនក្នុងនិងក្រៅប្រទេសសម្រាប់ចំណាយវិនិយោគ។ |
| | | 75171 | ចំណូលពីប្រជាពលរដ្ឋ-សប្បុរសជនក្នុងនិងក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | ចំណូលដែលបានពីប្រជាពលរដ្ឋ សប្បុរសជនក្នុងនិងក្រៅប្រទេសសម្រាប់ចំណាយវិនិយោគ។ |
| | 7518 | | ចំណូលពីប្រភពផ្សេងៗ សម្រាប់ចំណាយវិនិយោគ | ចំណូលទទួលបានពីប្រភពផ្សេងៗទៀតសម្រាប់ចំណាយមូលធនក្រៅពីអនុគណនីទាំងខាងលើ។ |
| | | 75181 | ចំណូលពីប្រភពផ្សេងៗ សម្រាប់ចំណាយវិនិយោគ | ចំណូលទទួលបានពីប្រភពផ្សេងៗទៀតសម្រាប់ចំណាយមូលធនក្រៅពីអនុគណនីទាំងខាងលើ។ |
| 76 | | | ផលហិរញ្ញវត្ថុ | កត់ត្រាចំណូលទទួលបានពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ដូចជាការប្រាក់ទទួលបាន, ចំណេញពីការប្តូរប្រាក់។ |
| | 7601 | | ការប្រាក់នៃការឱ្យខ្ចីនិងការប្រាក់នៃប្រាក់បញ្ញើ | ចំណូលជាការប្រាក់ពីការឱ្យខ្ចីនូវមូលធន។ |
| | | 76011 | ការប្រាក់លើការឱ្យខ្ចី | ចំណូលពីការប្រាក់លើការឱ្យខ្ចី។ |
| | | 76012 | ការប្រាក់លើភតិសន្យាហិរញ្ញវត្ថុ | ចំណូលពីការប្រាក់លើភតិសន្យាហិរញ្ញវត្ថុ។ |
| | | 76013 | ការប្រាក់នៃប្រាក់បញ្ញើ | ចំណូលបានមកពីការប្រាក់នៃគណនីប្រាក់បញ្ញើនៅធនាគារ ឬ ស្ថាប័នហិរញ្ញវត្ថុ។ |
| | | 76018 | ចំណូលការប្រាក់ផ្សេងទៀត | ចំណូលពីការប្រាក់ផ្សេងទៀត ក្រៅពីអនុគណនីខាងលើ។ |
| | 7602 | | អន្តរការីយកម្ម | ចំណូលទទួលបានពីអន្តរការីយកម្ម។ |
| | | 76021 | អន្តរការីយកម្មនៃទីផ្សារមូលបត្រ | ចំណូលទទួលបានពីការបង់ជាភាគរយដោយទីផ្សារមូលបត្រ។ |
| | | 76022 | អន្តរការីយកម្មនៃទីផ្សារធានារ៉ាប់រង | ចំណូលទទួលបានពីការបង់ជាភាគរយនៃការលក់បណ្ណធានារ៉ាប់រង។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | | 76023 | អន្តរការីយកកម្រៃទីផ្សារអចលនវត្ថុ | ចំណូលទទួលបានពីការបង់ជាភាគរយដោយក្រុមហ៊ុនអចលនទ្រព្យក្នុងការទិញ និងលក់អចលនទ្រព្យ។ |
| | 7603 | | ភតិសន្យា | ចំណូលទទួលបានពីការបង់ជាភាគរយដោយក្រុមហ៊ុនទិញសម្ភារលើការទទួលបានលិខិតធានាដើម្បីខ្ចីលុយពីធនាគារ។ |
| | | 76031 | ភតិសន្យា | ចំណូលទទួលបានពីការបង់ជាភាគរយដោយក្រុមហ៊ុនទិញសម្ភារលើការទទួលបានលិខិតធានាដើម្បីខ្ចីលុយពីធនាគារ។ |
| | 7606 | | ចំណេញពីការប្តូរប្រាក់ | ចំណូលពីលំអៀងនៃការប្តូរប្រាក់។ |
| | | 76061 | ចំណេញពីការប្តូរប្រាក់ | ចំណូលពីលំអៀងនៃការប្តូរប្រាក់។ |
| | 7698 | | ផលហិរញ្ញវត្ថុផ្សេងទៀត | ចំណូលពីការគ្រប់គ្រងហិរញ្ញវត្ថុផ្សេងៗទៀត ដែលមិនស្ថិតនៅក្នុងគណនីខាងលើ ដូចជា៖ ចំណូលពីការបង្វែរបៀវត្សនិងប្រាក់បំណាច់ផ្សេងៗ សំណែសចំណាយឆ្លងឆ្នាំ។ |
| | | 76981 | ផលហិរញ្ញវត្ថុផ្សេងទៀត | ចំណូលពីការគ្រប់គ្រងហិរញ្ញវត្ថុផ្សេងៗទៀត ដែលមិនស្ថិតនៅក្នុងគណនីខាងលើ ដូចជា៖ ចំណូលពីការបង្វែរបៀវត្សនិងប្រាក់បំណាច់ផ្សេងៗ សំណែសចំណាយឆ្លងឆ្នាំ។ |
| 77 | | | ផលផ្សេងៗ និងផលពិសេស | ត្រូវបានកត់ត្រានៅក្នុងជំពូកនេះនូវចំណែកមួយនៃចំណូលតាមវិកា ដែលជាកំរិតផ្តួចផ្តើមរបស់រតនាគារជាតិ ឬ អាណាប័ក និងកត់ត្រាផងដែរនូវចំណូលពិតដែលបានពីការបោះផ្សាយប្រតិបត្តិការនៃការគ្រប់គ្រង (កម្រៃជើងសាររតនាគារ) ឬ ការប្រគល់ឱ្យនូវសកម្មអបលកម្មហិរញ្ញវត្ថុ ឬ មិនមែនហិរញ្ញវត្ថុ។ |
| | 7701 | | ចំណូលពីការបង់អតិរេក និងកម្រៃនៃកិច្ច-ប្រតិបត្តិការគ្រប់គ្រងផ្សេងៗ | ចំណូលទទួលបានពីសេវារតនាគារ និងអតិរេកថវិការាជធានី-ខេត្ត ក្រុង-ស្រុក។ |
| | | 77011 | ចំណូលពីការបង់អតិរេករបស់ថវិការាជធានី-ខេត្ត | ចំណូលទទួលបានពីអតិរេកថវិការាជធានី-ខេត្ត ក្រោយបញ្ចប់កិច្ចប្រតិបត្តិការចុងឆ្នាំ។ |
| | | 77012 | ចំណូលពីការបង់អតិរេករបស់ថវិកាក្រុង-ស្រុក | ចំណូលទទួលបានពីអតិរេកថវិកាក្រុង-ស្រុក ក្រោយបញ្ចប់កិច្ចប្រតិបត្តិការចុងឆ្នាំ។ |
| | | 77013 | កម្រៃរតនាគារ | ចំណូលទទួលបានពីការប្រើប្រាស់សេវារតនាគារក្នុងប្រតិបត្តិការបង្វែរប្រាក់ ដូចជា៖ ការបង្វែរលើគណនីបញ្ញើ...។ល។ |
| | | 77014 | ចំណូលពីការបង់អតិរេករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬអង្គភាពប្រហាក់ប្រហែល | ចំណូលទទួលបានពីអតិរេករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពប្រហាក់ប្រហែលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |
| | 7702 | | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | ចំណូលទទួលបានពីការលក់ និងលំអៀងនៃការដោះដូរទ្រព្យសម្បត្តិរដ្ឋ។ |
| | | 77021 | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ (លក់) | ចំណូលទទួលបានពីការលក់ និងលំអៀងនៃការដោះដូរទ្រព្យសម្បត្តិរដ្ឋ។ |
| | | 77022 | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ (ដោះដូរ) | ចំណូលទទួលបានពីការលក់ និងលំអៀងនៃការដោះដូរទ្រព្យសម្បត្តិរដ្ឋ។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | 7703 | | ចំណូលពីការលក់ដី រ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ | ចំណូលនេះបានមកពីការលក់ដីដែលមានរ៉ែ និងសម្បត្តិធម្មជាតិរបស់រដ្ឋទៅឱ្យឯកជនធ្វើអាជីវកម្ម។ |
| | | 77031 | ចំណូលពីការលក់ដី រ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ | ចំណូលនេះបានមកពីការលក់ដីដែលមានរ៉ែ និងសម្បត្តិធម្មជាតិរបស់រដ្ឋទៅឱ្យឯកជនធ្វើអាជីវកម្ម។ |
| | 7704 | | ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ | ចំណូលនេះបានមកពីការលក់អគារ ដោយការជម្រះបញ្ជីសារពើភណ្ឌ។ |
| | | 77041 | ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ | ចំណូលនេះបានមកពីការលក់អគារ ដោយការជម្រះបញ្ជីសារពើភណ្ឌ។ |
| | 7705 | | ចំណូលពីការលក់រថយន្ត ឧបករណ៍ និងសម្ភារបរិក្ខារ ជាអចលនវត្ថុ | ចំណូលនេះបានមកពីការលក់ថបនកម្មបច្ចេកទេស សម្ភារឧបករណ៍ និងហត្ថឧបករណ៍ឧស្សាហកម្ម...។ល។ ដែលជាអចលនវត្ថុ។ |
| | | 77051 | ចំណូលពីការលក់ថបនកម្ម បច្ចេកទេស សម្ភារ និង ហត្ថឧបករណ៍ | ចំណូលនេះបានមកពីការលក់ថបនកម្មបច្ចេកទេស សម្ភារ ឧបករណ៍ និងហត្ថឧបករណ៍ឧស្សាហកម្ម (គ្រឿងម៉ាស៊ីនដែលប្រើប្រាស់ឧស្សាហកម្ម)។ |
| | | 77052 | ចំណូលពីការលក់រថយន្ត | ចំណូលនេះបានមកពីការលក់រថយន្ត។ |
| | | 77053 | ចំណូលពីការលក់ឧបករណ៍ដុនដូន | ចំណូលនេះបានមកពីការលក់នូវឧបករណ៍ដុនដូន ដូចជា÷ គ្រឿងចក្រ។ |
| | | 77054 | ចំណូលពីការលក់ឧបករណ៍ការិយាល័យនិង គ្រឿងសង្ហារឹម | ចំណូលនេះបានមកពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម (អង្គុលីលេខ, កុំព្យូទ័រ, ម៉ាស៊ីនថតចម្លង, ទូដាក់ឯកសារ, និងគ្រឿងសង្ហារឹម។ |
| | | 77055 | ចំណូលពីការលក់សម្ភារព័ត៌មានវិទ្យានិងទូរគមនាគមន៍ | ចំណូលនេះបានមកពីការលក់សម្ភារព័ត៌មានវិទ្យា និងទូរគមនាគមន៍។ |
| | 7798 | | ផលពិសេសផ្សេងៗទៀត | ចំណូលនេះបានមកពីចំណូលផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | | 77981 | ផលពិសេសផ្សេងៗទៀត | ចំណូលនេះបានមកពីចំណូលផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |
| | | | **ក្រុមទី ២ : ចំណូលតាមដីកា (ប្រភេទទី៣)** | ចំណូលមិនឆ្លងកាត់សាច់ប្រាក់។ |
| | | | **ប្រភេទទី ៣ : ចំណូលតាមដីកា (មិនឆ្លងកាត់សាច់ប្រាក់)** | ចំណូលមិនឆ្លងកាត់សាច់ប្រាក់។ |
| | | | **ខ.សរុបចំណូលមូលធន (ក្រុមទី១ + ក្រុមទី២)** | ចំណូលជាមូលធនប្រមូលផ្តុំគណនីទាំងឡាយដែលទាក់ទងនឹងមូលនិធិផ្ទាល់ ការខ្ចី និងបំណុលប្រហាក់ប្រហែល។ ចំណូលនេះរួមមាន÷ ចំណូលពិត និងចំណូលតាមដីកា។ |
| | | | **ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២)** | ចំណូលជាសាច់ប្រាក់ជាក់ស្តែង។ ចំណូលពិតរួមមាន÷ ចំណូលពីប្រភពផ្ទាល់ និងចំណូលពីប្រភពខាងក្រៅ។ |
| | | | **ប្រភេទទី១: ចំណូលពីប្រភពផ្ទាល់** | ចំណូលទទួលបានពីក្នុងប្រទេស។ ចំណូលនេះមានអចលកម្មហិរញ្ញវត្ថុ។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្ដីពន្យល់ពីមាតិកាគណនី |
|---|---|---|---|---|
| 26 | | | **ការវិនិយោគ** | ការលក់ពីការវិនិយោគក្នុងញាតិសម្ព័ន្ធនិងការវិនិយោគទុនរួមគ្នា ចំណែកភាគកម្មតាមសមាមាត្ររបស់អ្នកវិនិយោគដែលមាននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន...។ល។ |
| | 2601 | | ការវិនិយោគក្នុងញាតិសម្ព័ន្ធនិងការវិនិយោគទុនរួមគ្នា | ការលក់ពីការវិនិយោគក្នុងញាតិសម្ព័ន្ធនិងការវិនិយោគទុនរួមគ្នា។ |
| | | 26011 | ការវិនិយោគក្នុងញាតិសម្ព័ន្ធ | ជាការវិនិយោគមួយដែលធ្វើឡើងដោយអង្គភាពមួយទៅលើអង្គភាពមួយទៀតដែលអ្នកវិនិយោគមានឥទ្ធិពលសំខាន់ ហើយមិនមែនជាអង្គភាពគ្រប់គ្រងរួម និងមិនមែនជាភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន។ |
| | | 26012 | ការវិនិយោគទុនរួមគ្នា | រៀបរាប់អំពីការវិនិយោគមួយដែលត្រូវបានចងដោយកិច្ចសន្យាដែលភាគីពីរ ឬ ច្រើនបានប្តេជ្ញាអនុវត្តសកម្មភាពដែលជាកម្មវត្ថុនៃការគ្រប់គ្រងរួម។ |
| | | 26013 | ការវិនិយោគក្នុងសហគ្រាសសាធារណៈ | ការវិនិយោគនៅក្នុងសហគ្រាសសាធារណៈជាទំរង់នៃភាគហ៊ុនត្រូវបានគេពន្យល់ថា ជាការវិនិយោគដែលរាជរដ្ឋាភិបាលដាក់ទុនវិនិយោគដើម្បីទិញចំណែកខ្លះនៃភាគកម្មនៅក្នុងសហគ្រាសសាធារណៈ។ ឧទាហរណ៍ ការវិនិយោគរបស់រាជរដ្ឋាភិបាលនៅក្នុងទូរគមនាគមន៍កម្ពុជា (Telecom Cambodia) ជាដើម...។ល។ |
| 27 | | | **ប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗ** | ចំណូលប្រភេទនេះរួមមានតម្លៃដែលទទួលបានក្នុងក្របខ័ណ្ឌនៃការចល័តថវិកា ដូចជា៖ តម្លៃដែលបានទទួលដោយការឲ្យខ្ចី (ភាគហ៊ុន ឬ មូលបត្រ)។ |
| | 2701 | | ការឲ្យខ្ចី (ការសងវិញនូវមូលធន) | ចំណូលពីការសងមកវិញនូវការឲ្យខ្ចី (ការសងវិញនូវមូលធន)។ |
| | | 27011 | ការឲ្យខ្ចី ទៅសហគ្រាសសាធារណៈ | ចំណូលពីការសងមកវិញនូវការឲ្យខ្ចីទៅសហគ្រាសសាធារណៈ (ដូចជា៖ រដ្ឋាករទឹកស្វយ័តភ្នំពេញ, អគ្គិសនីកម្ពុជា, កំពង់ផែភ្នំពេញ, កាំសាប, ក្រុមហ៊ុនហ្វ្រីនត្រេដ, ធនាគារអភិវឌ្ឍន៍ជនបទ...)។ |
| | | 27012 | ការឲ្យខ្ចី ទៅសហគ្រាសឯកជន | ចំណូលពីការសងមកវិញនូវការឲ្យខ្ចីទៅសហគ្រាសឯកជន (ដូចជា៖ ធនាគារអេស៊ីលីដា, ធនាគារកាណាឌីយ៉ា ...)។ |
| | | 27013 | ការឲ្យខ្ចី ទៅអង្គការមិនមែនរដ្ឋាភិបាល | ចំណូលពីការសងមកវិញនូវការឲ្យខ្ចីទៅអង្គការមិនមែនរដ្ឋាភិបាល។ |
| | | 27018 | ការឲ្យខ្ចីផ្សេងៗ | ចំណូលពីការសងមកវិញនូវការឲ្យខ្ចីផ្សេងៗ។ |
| | | | **ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ** | ចំណូលទទួលបានពីក្រៅប្រទេស។ ចំណូលនេះរួមមានការខ្ចីនិងបំណុលប្រហាក់ប្រហែល។ |
| 50 | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | កត់ត្រាចំណូលទទួលបានពីការខ្ចីប្រាក់ក្នុងប្រទេស និងក្រៅប្រទេស។ |
| | 5001 | | ការខ្ចីប្រាក់ក្នុងប្រទេស | ចំណូលទទួលបានពីការខ្ចីប្រាក់ក្នុងប្រទេស។ |
| | | 50011 | ធនាគារជាតិនៃកម្ពុជា | ចំណូលទទួលបានពីការខ្ចីប្រាក់តាមរយៈធនាគារជាតិនៃកម្ពុជា។ |
| | | 50012 | ធនាគារពាណិជ្ជ | ចំណូលទទួលបានពីការខ្ចីប្រាក់ តាមរយៈធនាគារពាណិជ្ជ។ |
| | | 50018 | ផ្សេងៗ | ចំណូលទទួលបានពីការខ្ចីប្រាក់ក្នុងប្រទេសផ្សេងៗទៀត ក្រៅពីអនុគណនីខាងលើ។ |

| ជំពូក | គណនី | អនុគណនី | ឈ្មោះគណនី | សេចក្តីពន្យល់ពីមាតិកាថវិកា |
|---|---|---|---|---|
| | 5002 | | ការខ្ចីក្រៅប្រទេស | ចំណូលពីការខ្ចីបុលក្រៅប្រទេសពីពហុភាគីដូចជា (ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម...)។ |
| | | 50021 | ការខ្ចីក្រៅប្រទេស-ពហុភាគី | ចំណូលពីការខ្ចីបុលក្រៅប្រទេសពីពហុភាគីដូចជា (ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម...)។ |
| | | 50022 | ការខ្ចីក្រៅប្រទេស-ទ្វេភាគី | ចំណូលពីការខ្ចីបុលក្រៅប្រទេស-ទ្វេភាគីដូចជា (ជប៉ុន, បារាំង, អាឡឺម៉ង់...)។ |
| | 5004 | | ការខ្ចីពីទីផ្សារហិរញ្ញវត្ថុ | ចំណូលពីការខ្ចីពីទីផ្សារហិរញ្ញវត្ថុ។ |
| | | 50041 | សញ្ញាប័ណ្ណ | ចំណូលពីការលក់សញ្ញាប័ណ្ណដែលបោះផ្សាយដោយរដ្ឋាភិបាល។ |
| | | 50042 | ប័ណ្ណរដ្ឋាភិបាល | ចំណូលពីប័ណ្ណរដ្ឋាភិបាល។ |

# សេចក្តីព្រាងឧបសម្ព័ន្ធចំណាត់ថ្នាក់មុខងារ

| កូដមុខងារ | កូដអនុមុខងារ | កូដអនុអនុមុខងារ | បរិយាយ | សេចក្តីពន្យល់ |
|---|---|---|---|---|
| ៧០១ | | | សេវាកម្មសាធារណៈទូទៅ | |
| | ៧០១១ | | អង្គនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ កិច្ចការហិរញ្ញវត្ថុ សារពើពន្ធ និងកិច្ចការបរទេស | |
| | | ៧០១១១ | អង្គនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ | -ការគ្រប់គ្រង ដំណើរការ ឬការគាំទ្ររបស់អង្គនីតិប្បញ្ញត្តិ ដែលពុំអាចកំណត់មុខងារជាក់លាក់ ដូចជា÷ ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ល។ អង្គនីតិប្រតិបត្តិ ដែលពុំអាចកំណត់មុខងារជាក់លាក់ ដូចជា÷ ក្រសួងព្រះបរមរាជវាំង ធនាគារជាតិនៃកម្ពុជា ទីស្តីការគណៈរដ្ឋមន្ត្រី សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ល។ រួមទាំងទីប្រឹក្សាផ្នែករដ្ឋបាល និងនយោបាយអមអង្គនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ<br>+មិនរាប់បញ្ចូល÷ ការិយាល័យថ្នាក់ដឹកនាំក្រសួង ស្ថាប័ន គណៈកម្មាធិការអន្តរក្រសួង ជាដើម ដែលអាចកំណត់មុខងារជាក់លាក់ (បែងចែកទៅតាមចំណាត់ថ្នាក់មុខងារ)។ |
| | | ៧០១១២ | កិច្ចការហិរញ្ញវត្ថុ និងសារពើពន្ធ | -ការគ្រប់គ្រងកិច្ចការ សេវាហិរញ្ញវត្ថុ និងសារពើពន្ធ, ការគ្រប់គ្រងមូលនិធិសាធារណៈ និងបំណុលសាធារណៈ, ដំណើរការនៃផែនការប្រមូលពន្ធ, ដំណើរការសេវាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អាជ្ញាធរប្រមូលចំណូល អង្គភាពរៀបចំថវិកា......), សេវាគណនេយ្យ និងសវនកម្ម ដូចជាអាជ្ញាធរសវនកម្មជាតិ ក្រុមប្រឹក្សាជាតិគណនេយ្យ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។ល។<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្តីពីកិច្ចការហិរញ្ញវត្ថុ និងសារពើពន្ធ |

| | | | | |
|---|---|---|---|---|
| | | | | +រួមបញ្ចូលទាំង៖ កិច្ចការ សេវាហិរញ្ញវត្ថុ និងសារពើពន្ធនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>+មិនរួមបញ្ចូល៖ ការទូទាត់ការប្រាក់ ការធានាទិញមូលប័ត្របំណុលរបស់រាជរដ្ឋាភិបាល និងការសងប្រាក់ដើម (ដែលបានកំណត់នៅក្នុង ៧០១៧០), ការត្រួតពិនិត្យវិស័យធនាគារ (ដែលបានកំណត់នៅក្នុង ៧០៤១១)។ |
| | | ៧០១១៣ | កិច្ចការបរទេស | ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងកិច្ចការបរទេស ដំណើរការ ការគាំទ្រ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បេសកកម្មកុងស៊ុល ការិយាល័យប្រចាំអង្គការអន្តរជាតិ បណ្ណាល័យ ការិយាល័យដែលបម្រើឱ្យវប្បធម៌ និងព័ត៌មាន ដែលមានទីតាំងនៅក្រៅប្រទេស ការបង់វិភាគទានដល់អង្គការអន្តរជាតិនានា<br>+មិនរួមបញ្ចូល៖ ជំនួយផ្នែកសេដ្ឋកិច្ចទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានការអភិវឌ្ឍតិចតួច(ដែលបានកំណត់នៅក្នុង ៧០១២១), បេសកកម្មជំនួយផ្នែកសេដ្ឋកិច្ចទៅរដ្ឋាភិបាលក្រៅប្រទេស (ដែលបានកំណត់នៅក្នុង ៧០១២១), ការចូលរួមចំណែកតាមលទ្ធភាពទៅក្នុងកម្មវិធីជំនួយដល់អង្គការអន្តរជាតិ ឬតំបន់ (ដែលបានកំណត់នៅក្នុង ៧០១២២), អង្គភាពយោធាប្រចាំការនៅក្រៅប្រទេស (ដែលបានកំណត់នៅក្នុង៧០២១០), ជំនួយយោធាទៅក្រៅប្រទេស (ដែលបានកំណត់នៅក្នុង ៧០២៣០), កិច្ចការសេដ្ឋកិច្ច និងពាណិជ្ជកម្មបរទេស (ដែលបានកំណត់នៅក្នុង ៧០៤១១), កិច្ចការ និងសេវាកម្មទេសចរណ៍ (ដែលបានកំណត់នៅក្នុង ៧០៤៧៣)។ |
| | ៧០១២ | | ជំនួយសេដ្ឋកិច្ចទៅក្រៅប្រទេស | |
| | | ៧០១២១ | ជំនួយសេដ្ឋកិច្ចទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច | ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច ដំណើរការ ការគាំទ្រ នៃកម្មវិធីជំនួយបច្ចេកទេស កម្មវិធីបណ្តុះបណ្តាល និងអាហារូបករណ៍។ ហិរញ្ញប្បទានឥតសំណងផ្នែកសេដ្ឋកិច្ច អាចជាសាច់ប្រាក់ ឬមិនមែនសាច់ប្រាក់ ឬហិរញ្ញប្បទានសហប្រតិបត្តិការដោយមិនមានការប្រាក់ |

| | | | | |
|---|---|---|---|---|
| | | | | +មិនរាប់បញ្ចូល៖ ការចូលរួមចំណែកតាមលទ្ធភាពទៅក្នុងកម្មវិធីជំនួយដល់អង្គការអន្តរជាតិ ឬតំបន់ (ដែលបានកំណត់នៅក្នុង ៧០១២២) ជំនួយយោធាទៅក្រៅប្រទេស (ដែលបានកំណត់នៅក្នុង ៧០២៣០)។ |
| | | ៧០១២២ | ជំនួយសេដ្ឋកិច្ចតាមរយៈអង្គការអន្តរជាតិ | ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងជំនួយសេដ្ឋកិច្ចតាមរយៈអង្គការអន្តរជាតិ។ វិភាគទានអាចជាសាច់ប្រាក់ ឬមិនមែនសាច់ប្រាក់ដល់មូលនិធិអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលគ្រប់គ្រងដោយអង្គការអន្តរជាតិក្នុងតំបន់ ឬអង្គការផ្សេងៗទៀត<br>+មិនរួមបញ្ចូល៖ ជំនួយសម្រាប់ដំណើរការរក្សាសន្តិភាពអន្តរជាតិ (ដែលបានកំណត់នៅក្នុង ៧០២៣០)។ |
| | ៧០១៣ | | សេវាកម្មទូទៅ | សេវាកម្មទូទៅនេះ គ្របដណ្តប់លើសេវាកម្មទូទៅដែលមិនបម្រើឱ្យមុខងារជាក់លាក់ណាមួយ។ |
| | | ៧០១៣១ | សេវាបុគ្គលិកទូទៅ | -ការគ្រប់គ្រង និងដំណើរការនៃសេវាបុគ្គលិកទូទៅ រួមមានការរៀបចំ និងការអនុវត្តគោលនយោបាយបុគ្គលិកទូទៅ នីតិវិធីនៃការជ្រើសរើស ការដំឡើងឋានៈ ការរៀបចំតួនាទីនិងភារៈកិច្ច ការវាយតម្លៃ។ល។<br>+មិនរាប់បញ្ចូល៖ ការគ្រប់គ្រង និងសេវាផ្នែកបុគ្គលិកដែលត្រូវបានកំណត់តាមមុខងារជាក់លាក់ |
| | | ៧០១៣២ | សេវាផែនការ និងស្ថិតិ | -ការគ្រប់គ្រង និងដំណើរការនៃសេវាផែនការ និងស្ថិតិរួមមាន ការរៀបចំ ការសម្របសម្រួល ការពិនិត្យតាមដាន និងផ្សព្វផ្សាយផែនការសេដ្ឋកិច្ច សង្គម និងស្ថិតិ<br>+មិនរាប់បញ្ចូល៖ ផែនការសេដ្ឋកិច្ច សង្គម និងស្ថិតិ ដែលត្រូវបានកំណត់តាមមុខងារជាក់លាក់ |
| | | ៧០១៣៣ | សេវាទូទៅផ្សេងៗទៀត | ការគ្រប់គ្រង និងសេវាទូទៅ ពាក់ព័ន្ធនឹងសេវាកម្មទូទៅ ហើយមិនបានកំណត់ក្នុង (៧០១៣១ និង ៧០១៣២)<br>មិនរួមបញ្ចូល៖ សេវាទូទៅដទៃផ្សេងទៀតដែលជាប់ពាក់ព័ន្ធនឹងមុខងារជាក់លាក់ (ដែលបានបែងចែកទៅតាមមុខងារ)។ |

| | | | | |
|---|---|---|---|---|
| | ៧០១៤ | | ការស្រាវជ្រាវជាមូលដ្ឋាន | ការស្រាវជ្រាវជាមូលដ្ឋាន គឺជាការពិសោធន៍ផ្នែកទ្រឹស្តី ឬការអនុវត្ត ដែលត្រូវបានធ្វើឡើងជាបឋម ដើម្បីទទួលបានចំណេះដឹងថ្មីជាមូលដ្ឋានគ្រឹះ។ |
| | | ៧០១៤០ | ការស្រាវជ្រាវជាមូលដ្ឋាន | -ការគ្រប់គ្រង និងដំណើរការដែលបានចូលរួមក្នុងការស្រាវជ្រាវជាមូលដ្ឋាន<br>-ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវជាមូលដ្ឋានដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាលដូចជា វិទ្យាស្ថានស្រាវជ្រាវ ឬសាកលវិទ្យាល័យ<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវ និងការពិសោធន៍ដែលមានមុខងារច្បាស់លាស់។ |
| | ៧០១៥ | | ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍សេវាកម្មសាធារណៈទូទៅ | ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍សេវាសាធារណៈទូទៅ ដើម្បីសម្រេចគោលដៅជាក់លាក់ ដូចជា ផលិតសម្ភារ និងឧបករណ៍ថ្មីៗ ដើម្បីពង្រឹងគុណភាពសេវា។ |
| | | ៧០១៥០ | ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍សេវាកម្មសាធារណៈទូទៅ | -ការគ្រប់គ្រង និងដំណើរការដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ដើម្បីសម្រេចគោលដៅសេវាសាធារណៈទូទៅ<br>-ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន ដើម្បីគាំទ្រការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍សេវាសាធារណៈទូទៅ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជា វិទ្យាស្ថានស្រាវជ្រាវ ឬសាកលវិទ្យាល័យ<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន (ដែលបានកំណត់នៅក្នុង ៧០១៤០)។ |
| | ៧០១៦ | | សេវាកម្មសាធារណៈទូទៅផ្សេងៗ | |
| | | ៧០១៦០ | សេវាកម្មសាធារណៈទូទៅផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងសេវាកម្មសាធារណៈទូទៅផ្សេងៗដូចជា ការចុះបញ្ជីអ្នកបោះឆ្នោត ការរៀបចំការបោះឆ្នោត ការធ្វើប្រជាមតិ។ល។<br>+រួមបញ្ចូលទាំង÷ សេវាសាធារណៈទូទៅដែលមិនអាចកំណត់នៅក្នុង (៧០១១), (៧០១២), (៧០១៣), (៧០១៤), ឬ (៧០១៥)<br>+មិនរួមបញ្ចូល÷ ប្រតិបត្តិការបំណុលសាធារណៈ (ដែលបានកំណត់នៅក្នុង ៧០១៧); ការផ្ទេរឥណទានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ដែលបានកំណត់នៅក្នុង ៧០១៨)។ |

| | | | | |
|---|---|---|---|---|
| | ៧០១៧ | | ប្រតិបត្តិការបំណុលសាធារណៈ | |
| | | ៧០១៧០ | ប្រតិបត្តិការបំណុលសាធារណៈ | -ការទូទាត់ការប្រាក់ ការធានាទិញមូលប័ត្របំណុលរបស់រដ្ឋ និងការសងប្រាក់ដើម<br>+មិនរួមបញ្ចូល÷ចំណាយរដ្ឋបាលនៃការគ្រប់គ្រងបំណុលសាធារណៈ (ដែលបានកំណត់នៅក្នុង ៧០១១២)។ |
| | ៧០១៨ | | ការផ្ទេរឥណទានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | |
| | | ៧០១៨០ | ការផ្ទេរឥណទានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | -ការផ្ទេរឥណទានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈទូទៅ និងមិនអាចកំណត់មុខងារជាក់លាក់។ |
| ៧០២ | | | ការការពារជាតិ | |
| | ៧០២១ | | ការការពារជាតិផ្នែកយោធា | |
| | | ៧០២១០ | ការការពារជាតិផ្នែកយោធា | -ការគ្រប់គ្រង និងសេវាការពារជាតិផ្នែកយោធា ពាក់ព័ន្ធនឹងដំណើរការ ការគាំទ្រកម្លាំងយោធាជើងគោក ជើងទឹក ជើងអាកាស វិស្វកម្ម ដឹកជញ្ជូន ទំនាក់ទំនង ចារកម្ម និងកងកម្លាំងគាំទ្រផ្សេងទៀត<br>+រួមបញ្ចូលទាំង÷ការិយាល័យសេនានុព័ន្ធប្រចាំការនៅក្រៅប្រទេស មន្ទីរពេទ្យយោធាតាមភូមិភាគ និងមូលដ្ឋាន<br>+មិនរួមបញ្ចូល÷ បេសកកម្មជំនួយយោធាបរទេស (ដែលបានកំណត់នៅក្នុង ៧០២៣០) មន្ទីរពេទ្យ និងមណ្ឌលសុខភាព (ដែលបានកំណត់នៅក្នុង ៧០៧៣) សាលា និងមហាវិទ្យាល័យយោធា ដែលមានកម្មវិធីសិក្សាស្រដៀងគ្នាទៅនឹងគ្រឹះស្ថានបណ្តុះបណ្តាលស៊ីវិល បើទោះជាអ្នកចូលរួមកំណត់ត្រឹមមន្ត្រីយោធា និងក្រុមគ្រួសារយោធា (ដែលបានកំណត់នៅក្នុង ៧០៩១, ៧០៩២, ៧០៩៣ ឬ ៧០៩៤) និងប្រាក់សោធននិវត្តន៍សម្រាប់មន្ត្រីយោធា (៧១០២)។ |

| | | | | |
|---|---|---|---|---|
| | ៧០២២ | | ការការពារជាតិផ្នែកស៊ីវិល | |
| | | ៧០២២០ | ការការពារជាតិផ្នែកស៊ីវិល | -ការគ្រប់គ្រង និងសេវាការពារជនស៊ីវិល ពាក់ព័ន្ធនឹងការរៀបចំផែនការ ការហ្វឹកហ្វឺន ដំណើរការ ឬការគាំទ្រដល់កងកម្លាំងសម្រាប់ការពារជនស៊ីវិល ដើម្បីទប់ទល់ហេតុការណ៍ដែលអាចកើតមានឡើងជាយថាហេតុ<br>+មិនរួមបញ្ចូល÷ សេវាអគ្គិភ័យសម្រាប់ការពារជនស៊ីវិល (ដែលបានកំណត់នៅក្នុង ៧០៣២០) ការទិញ ការស្តុកស្បៀងអាហារ ឧបករណ៍ និងសម្ភារៈផ្សេងៗសម្រាប់ប្រើប្រាស់បន្ទាន់ជួយជនស៊ីវិលក្នុងករណីមានគ្រោះមហន្តរាយកើតឡើង (ដែលបានកំណត់នៅក្នុង ៧១០៩០)។ |
| | ៧០២៣ | | ជំនួយយោធាទៅក្រៅប្រទេស | |
| | | ៧០២៣០ | ជំនួយយោធាទៅក្រៅប្រទេស | -ការគ្រប់គ្រង ដំណើរការបេសកកម្មនិងជំនួយផ្នែកយោធា ពីរដ្ឋាភិបាលទៅអង្គការ ឬសម្ព័ន្ធយោធាអន្តរជាតិ<br>-ជំនួយបរទេសផ្នែកយោធាអាចជា (១) ហិរញ្ញប្បទានឥតសំណង (ជាសាច់ប្រាក់ ឬជាសម្ភារ) (២) ហិរញ្ញប្បទានសហប្រតិបត្តិការមិនមានការប្រាក់ ឬហិរញ្ញប្បទានសហប្រតិបត្តិការផ្នែកសម្ភារ ដល់កងកម្លាំងរក្សាសន្តិភាពអន្តរជាតិ រួមទាំងការបណ្តុះបណ្តាលកងកម្លាំងផងដែរ។ |
| | ៧០២៤ | | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ការការពារជាតិ | |
| | | ៧០២៤០ | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ការការពារជាតិ | -ការគ្រប់គ្រង និងដំណើរការដែលបានចូលរួមក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងការការពារជាតិ<br>-ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកការការពារជាតិ ដែលអនុវត្តដោយអង្គភាពមិនមែនរដ្ឋាភិបាល ដូចជាវិទ្យាស្ថានស្រាវជ្រាវ ឬសាកលវិទ្យាល័យ<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន (ដែលបានកំណត់នៅក្នុង ៧០១៤០)។ |

| | | | | |
|---|---|---|---|---|
| | ៧០២៥ | | ការការពារជាតិផ្សេងៗ | |
| | | ៧០២៥០ | ការការពារជាតិផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការការពារជាតិ ហើយមិនបានកំណត់ក្នុង (៧០២១, ៧០២២, ៧០២៣, ឬ ៧០២៤)<br>+មិនរួមបញ្ចូល÷ ការគ្រប់គ្រងការងារអតីតយុទ្ធជនសង្គ្រាម (ដែលបានកំណត់នៅក្នុង ៧១០២)។ |
| ៧០៣ | | | សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ | |
| | ៧០៣១ | | សេវានគរបាល | |
| | | ៧០៣១០ | សេវានគរបាល | -ការគ្រប់គ្រង និងសេវានគរបាល ពាក់ព័ន្ធនឹងការចុះបញ្ជីជនបរទេស ការចេញឯកសារការងារនិងធ្វើដំណើរឱ្យជនអន្តោប្រវេសន៍ ការរក្សាទុកនូវរាល់ឯកសារនៃការគ្រប់គ្រងប្រជាពលរដ្ឋ ការរៀបចំ និងត្រួតពិនិត្យបទប្បញ្ញត្តិចរាចរណ៍ផ្លូវគោក ការទប់ស្កាត់ការរត់ពន្ធ និងការទប់ស្កាត់បទល្មើសនៃសាទជាដើម<br>-ប្រតិបត្តិការនៃកងកម្លាំងនគរបាលទូទៅ ការគាំទ្រកម្មវិធីបណ្តុះបណ្តាល ឬដំណើរការមន្ទីរពិសោធន៍របស់នគរបាល<br>+រួមបញ្ចូលទាំង÷ នគរបាលចរាចរណ៍<br>+មិនរួមបញ្ចូល÷ សាលានគរបាល ដែលផ្តល់ការអប់រំទូទៅបន្ថែមលើការបណ្តុះបណ្តាលនគរបាល ដែលបានកំណត់នៅក្នុង (៧០៩១),៧០៩២),(៧០៩៣) ឬ(៧០៩៤)។ |
| | ៧០៣២ | | សេវាការពារអគ្គិភ័យ | |
| | | ៧០៣២០ | សេវាការពារអគ្គិភ័យ | -ការគ្រប់គ្រង និងសេវា ពាក់ព័ន្ធនឹងការការពារ ការពន្លត់ ឬកម្មវិធីបណ្តុះបណ្តាលការពន្លត់អគ្គិភ័យ<br>+រួមបញ្ចូលទាំង÷ សេវាការពារជនរងគ្រោះ ដូចជាការជួយសង្គ្រោះប្រជាជននៅតំបន់ភ្នំ តំបន់ឆ្នេរខ្សាច់ តំបន់ទឹកជំនន់។ល។<br>+មិនរួមបញ្ចូល÷ ការការពារជនស៊ីវិល (ដែលបានកំណត់នៅក្នុង ៧០២២០) ការបណ្តុះបណ្តាល និងបំពាក់សម្ភារសម្រាប់កងកម្លាំងបង្ការ និងពន្លត់ភ្លើងឆេះព្រៃ(ដែលបានកំណត់នៅក្នុង ៧០៤២២)។ |

| | | | | |
|---|---|---|---|---|
| | ៧០៣៣ | | តុលាការ | |
| | | ៧០៣៣០ | តុលាការ | -ការគ្រប់គ្រង ដំណើរការ ការគាំទ្រ តុលាការស៊ីវិល (រដ្ឋប្បវេណី និងព្រហ្មទណ្ឌ) និងប្រព័ន្ធយុត្តិធម៌ រួមមានការអនុវត្តការជាកពិន័យ ការដោះស្រាយតាមផ្លូវច្បាប់ ដែលសម្រេចដោយតុលាការ ដំណើរការដោះលែង និងការព្យួរទោសដោយមានលក្ខខណ្ឌ<br>-ការផ្តល់ប្រឹក្សា ឬតំណាងផ្នែកច្បាប់ក្នុងនាមរដ្ឋាភិបាល ឬភាគីផ្សេងៗ ដែលផ្តល់ដោយរដ្ឋាភិបាលជាសាច់ប្រាក់ ឬសេវាកម្មផ្លូវច្បាប់<br>+រួមបញ្ចូលទាំង÷ សាលាក្តីរដ្ឋបាល ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងអង្គភាពប្រហាក់ប្រហែល<br>+មិនរួមបញ្ចូល÷ រដ្ឋបាលពន្ធនាគារ (ដែលបានកំណត់នៅក្នុង ៧០៣៤០)។ |
| | ៧០៣៤ | | ពន្ធនាគារ | |
| | | ៧០៣៤០ | ពន្ធនាគារ | -ការគ្រប់គ្រង ដំណើរការ ឬការគាំទ្រពន្ធនាគារ និងកន្លែងផ្សេងទៀតសម្រាប់ការឃុំខ្លួន ឬការស្តារសម្បទា ដូចជាកសិដ្ឋាន រោងជាង មណ្ឌលកែប្រែ និងមជ្ឈមណ្ឌលសម្រាប់ជនវិកលចរិត ដែលបានប្រព្រឹត្តិបទល្មើស។ល។ |
| | ៧០៣៥ | | ការស្រាវជ្រាវ និងអភិវឌ្ឍន៍សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ | |
| | | ៧០៣៥០ | ការស្រាវជ្រាវ និងអភិវឌ្ឍន៍សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ | -កិច្ចការដែលពាក់ព័ន្ធនឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ<br>-ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន ដើម្បីគាំទ្រការស្រាវជ្រាវ និងអភិវឌ្ឍន៍សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល ដូចជាវិទ្យាស្ថានស្រាវជ្រាវ និងសាកលវិទ្យាល័យ<br>+មិនរួមបញ្ចូល÷ ការស្រាវជ្រាវជាមូលដ្ឋាន (ដែលបានកំណត់នៅក្នុង ៧០១៤០)។ |

| | | | | |
|---|---|---|---|---|
| | ៧០៣៦ | | សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈផ្សេងៗ | |
| | | ៧០៣៦០ | សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈផ្សេងៗ | -ការគ្រប់គ្រង និងសេវាការងារទូទៅ ពាក់ព័ន្ធនឹងការងារសុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ ដែលមិនបានកំណត់ក្នុង (៧០៣១), (៧០៣២), (៧០៣៣), (៧០៣៤) ឬ (៧០៣៥)។ |
| ៧០៤ | | | សេដ្ឋកិច្ច | |
| | ៧០៤១ | | សេដ្ឋកិច្ចទូទៅ ពាណិជ្ជកម្ម និងការងារ | |
| | | ៧០៤១១ | សេដ្ឋកិច្ចទូទៅ និងពាណិជ្ជកម្ម | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្ម<br>-បទប្បញ្ញត្តិ ឬការគាំទ្រសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដូចជាការជំរុញពាណិជ្ជកម្ម, ការនាំចេញ និងការនាំចូល។ល។<br>-ប្រតិបត្តិការ ឬការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធនឹងប្រកាសនីយប័ត្រ ពាណិជ្ជសញ្ញា សិទ្ធិថតចម្លង ការចុះបញ្ជីក្រុមហ៊ុន ការព្យាករអាកាសធាតុ បទដ្ឋាន ការវាស់ស្ទង់ធនធានទឹក ការវាស់វែងក្រឡាដី ការត្រួតពិនិត្យវិស័យធនាគារ។ល។<br>-ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន ដើម្បីលើកស្ទួយគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច និងពាណិជ្ជកម្ម<br>+រួមបញ្ចូលទាំង÷ ការអប់រំ និងការការពារអ្នកប្រើប្រាស់ដូចជាការពង្រឹង និងការត្រួតពិនិត្យការផ្ដល់អាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រសម្រាប់ការនាំចេញ ការនាំចូលតាមច្បាប់ និងបទប្បញ្ញត្តិពិពិធកម្មទីផ្សារ និងការអភិវឌ្ឍវិស័យឯកជន។ល។<br>+មិនរួមបញ្ចូល÷ កិច្ចការសេដ្ឋកិច្ច និងពាណិជ្ជកម្មនៃកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ដែលបានកំណត់នៅក្នុង ៧០៤២) និងឧស្សាហកម្មផ្សេងៗ (ដែលបានកំណត់នៅក្នុង ៧០៤៧)។ |

| | | | | |
|---|---|---|---|---|
| | | ៧០៤១២ | ការងារ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តគោលនយោបាយការងារ, ការត្រួតពិនិត្យ លក្ខខណ្ឌការងារដូចជា ចំនួនម៉ោងធ្វើការ ប្រាក់ខែ សុវត្ថិភាពការងារ។ល។<br>-ប្រតិបត្តិការ ឬការគាំទ្រកម្មវិធីទូទៅ ដើម្បីសម្របសម្រួលការងារ សំដៅកាត់បន្ថយការរើសអើងពូជសាសន៍ ភេទ អាយុ ឈានទៅកាត់បន្ថយអត្រាគ្មានការងារធ្វើ<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅដូចជា ឯកសារបច្ចេកទេស និងស្ថិតិស្តីពីការងារជាដើម<br>-ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន ដើម្បីលើកស្ទួយគោលនយោបាយ និងកម្មវិធីការងារទូទៅ<br>+មិនរួមបញ្ចូល÷ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ដែលបានកំណត់នៅក្នុង ៧០៤២), ឧស្សាហកម្មផ្សេងៗ (ដែលបានកំណត់នៅក្នុង ៧០៤៧) និងផ្តល់ការគាំពារពីសង្គមក្នុងទម្រង់ជាអត្ថប្រយោជន៍សាច់ប្រាក់ និងអត្ថប្រយោជន៍ជាសម្ភារ ចំពោះបុគ្គលដែលមិនមានការងារធ្វើ (ដែលបានកំណត់នៅក្នុង ៧១០៥០)។ |
| | ៧០៤២ | | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| | | ៧០៤២១ | កសិកម្ម | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យការងារកសិកម្ម ឬការពង្រីកផ្ទៃដីដែលអាចដាំដុះបាន កំណែទម្រង់ការបែងចែកដីធ្លីកសិកម្ម និងការតាំងទីលំនៅលើដីកសិកម្ម<br>-ការសាងសង់ ឬដំណើរការប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធស្រោចស្រព និងការការពារគ្រោះទឹកជំនន់ រួមទាំងហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន សម្រាប់ការងារនេះ<br>-ដំណើរការ ឬការគាំទ្រកម្មវិធីកសិកម្ម ដើម្បីរក្សាតុល្យភាព ឬលើកកម្ពស់តម្លៃលើផលិតផលកសិកម្ម និងប្រាក់ចំណូលពីការធ្វើកសិកម្ម<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្តីពីកិច្ចការ និងសេវាកសិកម្ម<br>-ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន សម្រាប់សកម្មភាពកសិកម្ម<br>+មិនរួមបញ្ចូល÷ គម្រោងអភិវឌ្ឍន៍ពហុគោលបំណង (ដែលបានកំណត់នៅក្នុង ៧០៤៧៤)។ |

| | | | | |
|---|---|---|---|---|
| | | ៧០៤២២ | ព្រៃឈើ | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យលើអាជីវកម្មព្រៃឈើ<br>-ដំណើរការ ឬការគាំទ្រលើការងារដាំដុះព្រៃឈើឡើងវិញ ការការពារសត្វល្អិត និងជំងឺឆ្លង សេវាពន្លត់ និងបង្ការភ្លើងឆេះព្រៃ និងផ្តល់សេវាជូនអ្នកអភិរក្សព្រៃឈើ។<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្តីពីព្រៃឈើ<br>-ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន សម្រាប់សកម្មភាពព្រៃឈើ<br>+រួមបញ្ចូលទាំង÷ ការដាំព្រៃឈើបន្ថែម។ |
| | | ៧០៤២៣ | ការនេសាទ និងប្រមាញ់ | ការនេសាទ និងការប្រមាញ់ជាលក្ខណៈពាណិជ្ជកម្ម និងជាលក្ខណៈកីឡា ដែលនៅក្រៅឧទ្យានជាតិ និងតំបន់អភិរក្សព្រៃឈើ<br>-ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យលើអាជីវកម្មនេសាទ និងការប្រមាញ់<br>-ដំណើរការ ឬការគាំទ្រទីកន្លែងភ្ញាស់ត្រី ទីកន្លែងសត្តឃាត។ល។<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិស្តីពីកិច្ចការ និងសេវានេសាទ និងការប្រមាញ់<br>-ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន សម្រាប់សកម្មភាពនេសាទ និងការប្រមាញ់<br>+មិនរួមបញ្ចូល÷ ការការពារការនេសាទនៅដែនសមុទ្រ (ដែលបានកំណត់នៅក្នុង ៧០៣១០) ការការពារប្រព័ន្ធជីវៈចម្រុះ និងដែនទេសភាព (ដែលបានកំណត់នៅក្នុង ៧០៥៤០)។ |
| | ៧០៤៣ | | ឥន្ធនៈ និងថាមពល | |
| | | ៧០៤៣១ | រ៉ែធ្យូងថ្ម និងរ៉ែប្រេងរឹង | -ការគ្រប់គ្រង និងសេវាកម្មការងារទូទៅ ពាក់ព័ន្ធនឹងការអភិរក្ស ការរុករក ការអភិវឌ្ឍ ការរៀបចំបទប្បញ្ញត្តិ និងត្រួតពិនិត្យការធ្វើអាជីវកម្មធនធានរ៉ែធ្យូងថ្ម និងរ៉ែប្រេងរឹងដែលអាចឆេះ<br>-ការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទូទៅ ឯកសារបច្ចេកទេស និងស្ថិតិ ស្តីពីកិច្ចការសេវារ៉ែធ្យូងថ្ម និងរ៉ែប្រេងរឹង |

| | | | | |
|---|---|---|---|---|
| | | | | -ហិរញ្ញប្បទានឥតសំណង, ហិរញ្ញប្បទានសហប្រតិបត្តិការ ឬឧបត្ថម្ភធន សម្រាប់សកម្មភាពរ៉ែត្បូងថ្ម និងរ៉ៃប្រេងរឹង<br>+មិនរួមបញ្ចូល៖ ការដឹកជញ្ជូនរ៉ែត្បូងថ្ម និងរ៉ែប្រេងរឹង (ដែលបានកំណត់នៅក្នុង ៧០៤៥)។ |
